# ព្រះរាជាណាចក្រ កម្ពុជា

មន្ទីរស្ដីការក្រសួងសិក្សាធិការ

# ទស្សនាវដ្ដី

សម្រាប់

គ្រូបង្រៀន

ឆ្នាំទី ២ លេខ ៤

ខែធ្នូ ព.ស. ២៤៩៣

ឆ្នាំសិក្សា ១៩៥០-៥១

BIBLIOTHÈQUE
NATIONALE
DU CAMBODGE
P.K.2
1950-1951
(4)

# ឧត្តមដ្ឋាន

## របៀបនិមន្តលោកធ្វើមេវត្ត

អ្នកស្រុកកសាងវត្តថ្មី ពីមុនមកផ្ដាប់ចំណុះវត្តណា ចូលចិត្តស្រឡាញ់ភិក្ខុ ឬ គ្រូសូត្ររូបណា ត្រូវនាំគ្នាទាំងប្រុសស្រីជាច្រើន ទៅសុំឲ្យលោកជាចៅអធិការវត្តនោះចាត់ភិក្ខុ ឬ គ្រូសូត្រនោះ មកធ្វើមេវត្តថ្មី ។ បើគ្មានកំណត់អង្គលោកណាទេ ក៏ស្រេចនៅលោកចៅអធិការ ចាត់លោកអង្គណា ដែលគួរធ្វើជាមេវត្តបាន ឲ្យមកធ្វើជាមេវត្តថ្មី ។ បើលោកព្រមចាត់ឲ្យហើយ, វត្តនោះមានភិក្ខុច្រើន សូមនិមន្ត ៤ ឬ ៥ រូបដែលខ្ពីវស្សាជាងមេវត្តថ្មី ឲ្យនិមន្តមកជាមួយមកគង់វត្តថ្មីផង ។ អ្នកស្រុកឲ្យអាចារ្យមើលឫក្សថ្ងៃនឹងទទួលលោកឲ្យចូលមកក្នុងវត្ត ។

អាចារ្យមើលឫក្សថ្ងៃពេលាល្អបានហើយ, ត្រូវរៀបរណ្ដាប់ក្នុងវត្ត ហើយនាំគ្នាទៅទទួលលោកពីវត្តមក ហែហមជាអុកធិក ទាំងលោកចៅអធិការជាមេវត្តថ្មី ក៏និមន្តមកជាមួយ ; លុះមកដល់វត្តហើយ អ្នកស្រុក ឬអាចារ្យ អុជទៀនធូបប្រាប់អ្នកតា ទេវតា ព្រះភូមិ នាងគង្ហីង ព្រះធរណី ថាបាននិមន្តលោកនាមនេះ មកគង់ធ្វើជាមេវត្ត ព្រមទាំង

ភិក្ខុជាបរិសទ្យ សូមឲ្យបានសេចក្ដីសុខចំរើនរុងរឿង ឋិតថេរចិរកាលតទៅ ៗ ដល់ពេលល្ងាច រៀបចំរើទព្រះបរិត្ត (សូត្រមន្ត) ព្រឹកឡើងប្រគេនភត្ត រួចវេរដី១ត្រវត្ត ព្រមទាំងសាលា កុដិ ពេង៍ទ១បោ·សថ ប្រគេនលោកមេវត្តថ្មី ជាសូរេបកិច្ច ៗ

ថ្ងៃក្រោយមក ត្រូវសុំអនុញ្ញាតចំពោះសម្ដេចសង្ឃរាជ សុំឲ្យតាំងលោកមេវត្តនេះជាទីចៅអធិការ, សម្ដេចទ្រង់បានអនុញ្ញាតតាំងជាចៅអធិការហើយ, ចៅអធិការនេះចូលថ្វាយបង្គំគាល់សម្ដេច ៗ ប្រទានទឹកស្រោចជាចៅអធិការ ឲ្យពរសព្ទសាធុការព្រមទាំងប្រគល់សញ្ញាប័ត្រ ៗ

ពន្យល់ពាក្យ .– ចៅអធិការ= លោកមេវត្ត, នាយកលើវត្តណាមួយ ៗ– ភិក្ខុជាបរិសទ្យ = ភិក្ខុដែលស្ម័គ្រចិត្តរួមគំនិតជាមួយ ៗ– ភត្ត= ចង្ហាន់ អាហារដែលប្រគេនលោក ៗ– សម្ដេចសង្ឃរាជ = ស្ដេចសង្ឃ សង្ឃដែលជាធំលើសង្ឃទាំងឡាយ ៗ

ពាក្យសួរ = ហេតុអ្វីបានជាអ្នកស្រុកឲ្យអាចារ្យមើលឫក្សថ្ងៃមុននឹងទទួលលោកមេវត្តថ្មី? លុះលោកមេវត្តថ្មីនិមន្តមកដល់វត្តហើយ អាចារ្យធ្វើអ្វី ? ដើម្បីនឹងតាំងលោកមេវត្តថ្មីជាចៅអធិការ ត្រូវធ្វើអ្វីខ្លះ ?

# មជ្ឈិមដ្ឋាន ទី២

## ពិធីបុណ្យដង្ហែព្រះសារីរិកធាតុ

កាលថ្ងៃចន្ទ ១៥ កើតខែពិសាខ ជាថ្ងៃបុណ្យវិសាខបូជា ឆ្នាំខាល ទោស័ក ព.ស. ២៤៩៣ ត្រូវនឹងថ្ងៃ ១ ខែឧសភា គ.ស. ១៩៥០នេះ ពួកពុទ្ធបរិសទ្យ ជាចំណុះជើងវត្ត បានសាមគ្គីស្រុះស្រួលបបួល រួបរួមគ្នា ចាត់ចែងធ្វើពិធីបុណ្យមួយដ៏ឧឡារិកនៅទីវត្តហៅថាៈ <<បុណ្យហែព្រះសារីរិកធាតុ>> ។ នៅវេលាម៉ោង ៤ រសៀល ពួកពុទ្ធបរិស័ទបានមកជួបជុំគ្នា នៅមុខវត្ត; បណ្ដាពួកពុទ្ធបរិស័ទដែលបានអញ្ជើញមកទាំងប៉ុន្មាន មានសន្ដានជ្រះថ្លាក្នុងព្រះពុទ្ធសាសនា មានហត្ថាកាន់យកគ្រឿងសក្ការៈបូជាដ៏វិចិត្រ រចនាដោយបុប្ផាផ្កាឈើស្រស់, ផ្កាក្រដាស, ទៀនធូប, គ្រឿងក្រអូប, ទង់ជាតិ ។ ឯគ្រឿងដំកើងលើកដម្កល់ព្រះសារីរិកធាតុនោះ ជាងធ្វើព្រះស្តូបរចនាដោយប្រាក់ ជាន់ខាងក្នុងរចនាជាកោដ្ឋមា.ប ហើយ ដាក់ព្រះធាតុដម្កល់ទុកក្នុងទូតបមួយជាន់ទៀត ។ គ្រឿងដម្កល់ហែ ជាងធ្វើជាបុស្បុកកំពស់ប្រមាណ ៥ ម៉ែត្រ ហើយដំកល់លើរថយន្ត

សណ្ដានមួយដ៏ប្រដាប់តាក់តែងដោយក្បូរក្បាច់រំលេច រចនាដោយផ្កាស្រស់ ផ្កាក្រដាសទន់ជាតិតូច ៗ នឹងគ្រឿងសក្ការៈ ផ្សេងៗ ទៀត ។

ក្នុងពេលនោះ គេក្រឡេកមើលពីចម្ងាយទៅ ឃើញក្រុមពុទ្ធបរិស័ទច្រើនមីរដេរដាស កាន់គ្រឿងសក្ការៈ បូជា ផ្លាស់ពណ៌ចំរុះទីទៃពីគ្នា គួរឲ្យមានសេចក្ដីរីករាយនឹងសេចក្ដីជ្រះថ្លាពន់ពេក ។

ពន្យល់ពាក្យ :— ព្រះសារីរិកធាតុ = ព្រះអដ្ឋិធាតុនៃព្រះសម្មាសម្ពុទ្ធ ។

ពួកពុទ្ធបរិស័ទ = ពួកដែលស្ម័គ្រចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនា.

ស្តូប = ចេតិយ

# មជ្ឈិមដ្ឋាន

## រៀនមើល – ពាក្យ – ហាត់ភាសា

### សេចក្ដីកតញ្ញូជាធំ

មានបុរសពីរនាក់ដឹកនាំចំណីអាហារ នូវផ្លែឈើផងទាំងឡាយ

ម្នាក់យកទៅសងគុណលោកអ្នកជាបុព្វការី ម្នាក់ទៀតយកទៅធ្វើបុណ្យ មួយបររទេះទៅ មួយបររទេះមក ជួនជួបប្រទះគ្នាពុំចៀសគ្នាឡើយ ហើយឈប់ឈ្លោះប្រកែកជជែកគ្នាជាយូរនៅទីនោះ លុះគ្រាតែខូចខាតបំណីអាហារអស់ ដោយដណ្ដើមផ្លូវគ្នា ។ ម្ល៉ោះហើយក៏នាំគ្នាទៅប្ដឹងចៅក្រម ៗ ទឹងជំនុំពិចារណាឲ្យពុំបាន ទើបនាំយកទៅក្រាបបង្គំទូលសម្ដេចព្រះមហាក្សត្រាធិរាជ ដល់ហើយចៅក្រមថ្វាយសេចក្ដីយ៉ាងខ្លីថា បុរសទាំងពីរនេះវិវាទគ្នាដោយបររទេះពុំចៀសគ្នា ។

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះសណ្ដាប់ហើយ ព្រះអង្គមានព្រះបន្ទូលត្រាស់ដណ្ដឹងថា ព្រះស្ដែងទាំងពីរបររទេះពុំព្រមចៀសគ្នានេះ តើដំណើរសេចក្ដីអំពីដើមដូចម្ដេច? ។

ចៅមួយក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំបររទេះផ្ទុកបំណីអាហារនឹងទៅធ្វើបុណ្យ ទៅប្រទះនឹងចៅនេះៗ ពុំព្រមចៀសឡើយ ។ ចៅមួយទៀតក្រាបទូលឡើងថា លោកដែលជាបុព្វការីមានគុណនឹងទូលព្រះបង្គំជាខ្ញុំ លោកមានធុរៈជាទម្ងន់ ហេតុនេះទូលព្រះបង្គំជាខ្ញុំដឹកនាំបណ្ណាការទៅបំពេញកិច្ចតបស្នងសងគុណលោក ជួនប្រទះនឹងរទេះចៅនេះ បរមកពុំព្រមចៀស ។

ដោយព្រះបញ្ញាមុតថ្ង ព្រះអង្គមានព្រះបន្ទូលកាត់សេចក្ដីថា ត្រូវឲ្យព្រះស្ដេចទៅធ្វើបុណ្យសងអស់របស់ព្រះស្ដេចដែលបំរុងទៅសងគុណគេនោះ ព្រោះការធ្វើបុណ្យនោះដោយចិត្តសទ្ធាឯង ៗ ពុំធ្វើដោយបំណាច់អ្វីឡើយ ឯព្រះស្ដេចដែលទៅសងគុណគេនោះ ដ្បិតកាលខ្លួនមានទុក្ខគេដោះទុក្ខខ្លួន ឥឡូវនេះដល់គេមានទុក្ខវិញ ព្រះស្ដេចនោះត្រូវទៅដោះទុក្ខតបស្នងសងគុណគេវិញហោង ៗ ហេតុដ្បិតតែព្រះស្ដេចមួយបររទេះពុំចៀស ទើបព្រះស្ដេចនេះខានទៅសងគុណគេ ៗ

ព្រះមហាក្សត្រិយ៍ទ្រង់ព្រះតម្រាស់ដោយប្រការដូច្នេះ បុរសទាំងពីរក៏សុខចិត្ត ហើយក្រាបថ្វាយបង្គំលានាំគ្នាទៅកាន់លំនៅអាត្មាឯទីទៃ ៗ ៗ ព្រះមហាក្សត្រាធិរាជកាត់សេចក្ដីនេះ ហៅថាសុគតិគមនំ ហោង ៗ

ពន្យល់ពាក្យ .– កតញ្ញូ = អ្នកដែលដឹងឧបការគុណដែលអ្នកឯទៀត:គេបានធ្វើហើយដល់ខ្លួន ៗ (មនុស្សកតញ្ញូ) ៗ

បុព្វការី = អ្នកដែលធ្វើឧបការៈមុន គឺអ្នកដែលបានធ្វើសេចក្ដីទំនុកបំរុងផ្គងផ្ដើមរួចមកហើយ (មាតាបិតាជាបុព្វការីរបស់កូន; គ្រូជាបុព្វការី

របស់សិស្ស ) ។ល។ បើជាស្ត្រីជាបុត្តការិនី ។ ធ្វើបុណ្យ = គឺធ្វើសេចក្ដីល្អខាងផ្លូវកាយ វាចា ចិត្ត ។ រំពង = ទាស់សំដីគ្នា ( ឈ្លោះប្រកែកគ្នា ) ។ បន្ទូល = សំដី , ការនិយាយ ( រាជសព្ទ )៖ ព្រះបន្ទូល , ទ្រង់មានព្រះបន្ទូល ។ ទូលព្រះបង្គំ = ( រាជសព្ទ ) ពាក្យសម្រាប់បុរសនិយាយហៅខ្លួនឯងទៅរកក្សត្រិយ៍ បើស្ត្រីប្រើពាក្យថា ខ្ញុំម្ចាស់ ។ បណ្ណាការ = ជំនូន , ក័ស្ដុការ , ជង្វាយ ។

សុគតិគមនំ = ប្រព្រឹត្តិទៅតាមដំណើរល្អ ( សមហេតុសមផល )

ពាក្យសួរ .- ក្នុងរឿងនេះគេនិយាយពីអ្វី ? - បុរសទាំងពីរនាក់កើតវិវាទនឹងគ្នាអំពីអ្វី ? - រឿងអ្នកទាំងពីរទៅជាអ្វីទៅ ? - ចៅក្រមជំរះសេចក្ដីនោះបាន ឬទេ ? - មហាក្សត្រិយ៍កាត់សេចក្ដីឲ្យបុរសណា ឈ្នះ ? - ព្រោះអ្វី ? - នរណា ជាបុត្តការីរបស់អ្នក ? ។

## សរសេរតាមសូត្រ

### អំពីជ្រួយដីហើយនឹងជំរះស្មៅ (ត)

(ក្សេត្រសាស្ត្រទំព័រ ៤៣ ពីការជំរះបំផ្លាញ ដល់ចប់)

សុំឲ្យលោកគ្រូ សរសេរពាក្យពីបាក នឹងពន្យល់បទវេយ្យាករណ៍ ឲ្យសិស្សបានឃើញ បានយល់ ដូចអាទិត្យមុនផង ។

## វិធីហាត់

ចូរឆ្លើយតាមពាក្យចោទខាងក្រោមនេះ ៖

១ –កាលណាគេដាំដំណាំ គេតែងតែដំរះស្មៅយកចេញពីដំណាំនោះ តើដើម្បីអ្វី ? ២ –វត្ថុអ្វីដែលហៅថាដី ? ៣– កាលអ្វីដែលហៅថាវស្សា · ប្រាំង? រដូវជាអ្វី? ។ ៤– ដុះនឹងដុសមានន័យប្លែកគ្នាដូចម្ដេច ? ( ដុះ = ប៉ិចពន្លក, បែកខ្នែង , លូតលាស់ចំរើន ; ដុស = ដូតលាង, ដំរះឲ្យស្អាតអស់មន្ទិល ) ។

# អាជិកដ្ឋាន

## បង្រៀនពាក្យ – ហាត់ភាសា

### អាទិត្យទី ១.– អំពីទីក្រុង

**នាម .–** កំង ប្រាសាទ វត្ត វិហារ ផ្ទះថ្ម រោងល្ខោន សាលា

មន្ទីររាជការ រោងម៉ាស៊ីន (រោងចក្រ) ឃ្លាំងជំនួញ ឃ្លាំងប្រាក់ ផ្សារ ផ្លូវ ថ្នល់ សួនច្បារ ម៉ាស៊ីនទឹក ចង្កៀងអគ្គិសនី យានជើងគោក (ថលយាន) យានជើងទឹក (ជលយាន) ទាហាន តម្រួត ប៉ូលិស ។

គុណនាម.— ស្គុកស្គម មាំមួន ប្រូងប្រាង ឆើតឆាយ ខ្នាន់ ខ្នាប់ ធំធេង ល្វឹងល្វើយ ស្អាត ភ្លឺផ្លេក ព្រោងព្រាត ស្រោងស្រឹង របៀបរៀង ត្រង់ រៀប ស្រស់ ស្រអាត់ រងំ ក្សេមក្សាន្ត ហឹហា រាបទាប បំព្រង ល្ហយល្ហង ប្រឹមប្រីយ ។

កិរិយាសព្ទ .— ដើរលេង ត្រាច់ ចរ យាត្រា រត់ ទៅ មក ទិញ លក់ ស៊ី ផឹក ជិះ ចរ ត្រួតត្រា ហាមឃាត់ បង្ហាញ នាំផ្លូវ ធ្វើការ សង់ រុះ រើ សែង រែក ទូល ជជែក ច្រៀង រាំ លេង ។

សេចក្ដីរំឭក .— សូមបង្រៀនពាក្យទាំងប៉ុន្មាននេះ ឲ្យបានគ្រប់គ្រាន់ក្នុងមួយអាទិត្យ ។

ហាត់ភាសា.— អ្នកមានស្គាល់ទីក្រុងណាមួយទេ ? នៅទីក្រុងនោះអ្នកឃើញអ្វីខ្លះ ? អ្នកឃើញផ្ទះនៅទីក្រុងយ៉ាងដូចម្ដេច ? ផ្លូវ

យ៉ាងដូចម្ដេច ? ទីក្រុងនោះតើជាអ្វី ? (..ជាទីប្រជុំជំ) ។ ទីក្រុងនឹងស្រុកស្រែប្លែកគ្នាយ៉ាងដូចម្ដេច ? ទីក្រុងធំនៃប្រទេសខ្មែរមាននាមហៅអ្វី ? ។

## បង្រៀនមើល-ហាត់ភាសា

### ក្រុងភ្នំពេញ

(សៀវភៅវិជ្ជាខេមរភាសា អាទិកថ្នាទំព័រ ១២២)

សូមកែតម្រូវពាក្យខ្លះ ៖ រង់រឿង=រុងរឿង ។ លប់=លុប

ហាត់ភាសា.– អ្នកដែលទៅក្រុងភ្នំពេញឬទេ? ភ្នំពេញគឺជាអ្វី? ក្រុងភ្នំពេញនៅកន្លែងណា?- កាលពីដើមទីកន្លែងក្រុងភ្នំពេញយ៉ាងដូចម្ដេច?- សព្វថ្ងៃនេះក្រុងភ្នំពេញយ៉ាងណា?- ថ្លុកត្រពាំងទៅណាអស់ទៅ?- មានអ្វីជំនួសឡើង?- នៅក្រុងភ្នំពេញ មានគេហស្ថានជាតិអ្វីខ្លះ? គេហស្ថាននោះយ៉ាងដូចម្ដេច?- អ្នកចង់ទៅលេងក្រុងភ្នំពេញឬទេ? ហេតុអ្វី?- ។

កាហាត់សរសេរ.– ចូរតែងជាឃ្លានឹងពាក្យខាងក្រោមនេះ ៖

ទីក្រុងធំ - គេហស្ថាន - និមិត្ត

## សរសេរតាមសូត្រ

### ក្រុងភ្នំពេញ

(សៀវភៅដដែលទំព័រ ១២២) ផ្នែកទី ១ តាំងពីមានទីក្រុងតិច រហូតដល់ . . . ឲ្យបានចម្រើនរុងរឿងឡើង; ផ្នែកទីពីរ តាំងពីលុបចុកគ្រពាំងរហូតដល់ចប់ ។

សរសេរពាក្យពិបាក.– រុងរឿង- ផុស- ព្រះធរណី- និមិត្ត- សុទ្ធតែ

---

ចុកគ្រពាំង- សុខក្សេមក្សាន្ត- គេហស្ថាន ។

## តែងសេចក្ដី

ចូរឆ្លើយតាមពាក្យចោទខាងក្រោមនេះ ៖

ទីក្រុងជាទីប្រជុំយ៉ាងដូចម្ដេច?- អ្នកឃើញមានអ្វីខ្លះក្នុងទីក្រុង?- គេហស្ថាននឹងផ្លូវផ្សានោះ តើយ៉ាងដូចម្ដេច?- គេឃើញមានបណ្ដាជនយ៉ាងដូចម្ដេច? ។

## អក្សរផ្ចង់

ប ប ម ហ ឋ

ហ ហា ហី ហូ ហួ ហើ ហៀ ហែ ហៃ ហោ

ហៅហួបេះហួប កុំហៃហែ កំហែងកំហល់ ហ្មឋារជាគ្រូលើ ហ្នាំងអស់ ។

## បង្រៀនពាក្យ – ហាត់ភាសា

### អាទិត្យទី ២ .– អំពីទីក្រុង(ត)

នាម – *ព្រះបរមរាជវាំង ព្រះករុណា ព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះទីនាំង-ចន្ទឆាយា ព្រះទីនាំងភោជនីយ ព្រះមហាប្រាសាទខេមរិន្ទ្រ ព្រះដំណាក់វៃ ៗ ស្វេតច្ឆត្រ ព្រះបល្ល័ង្ករាជ្យ ៗ ព្រះខាន់រាជ្យ ព្រះទីនាំងសំរិទ្ធិវិមាន ព្រះទីនាំងសម្រាន្តភិរម្យ ។*

គុណនាម .- រុងរឿង ថ្កុំថ្កើង ប្រពៃ ស្អាត ធំ ទូលាយ ប្រសើរ ។

កិរិយាសព្ទ .- ស្អាង ថ្វាយ គាល់បំរើ យាងទៅ គង់នៅ ផ្ទុំ សោយ ស្រង់ ទត ប្រទាន ។

ហាត់ភាសា.- អ្នកដែលឃើញព្រះបរមរាជវាំងឬទេ ? ព្រះបរមរាជវាំងនោះនៅឯណា? ព្រះបរមរាជវាំងនោះជាអ្វី? ប្រាសាទនីមួយៗ គេសម្រាប់ធ្វើអ្វី?- ក្នុងព្រះរាជពិធីបុណ្យអុំទូក ព្រះករុណាទ្រង់យាងទៅគង់នៅឯណា? ព្រះករុណាជាម្ចាស់ជីវិតលើត្បូង សព្វថ្ងៃនេះ ទ្រង់ឡើងសោយរាជសម្បត្តិពីថ្ងៃខែឆ្នាំណា? (៤ ៗ ៥ ១២ ឆ្នាំម្សាញ់ត្រីស័ក ព.ស. ២៤៨២ ត្រូវនឹងថ្ងៃ ២៤-៤-៤១)

ការហាត់សរសេរ - ចូរបន្ថែមពាក្យឲ្យពេញត្រឹមត្រូវនៅកន្លែងចន្លោះខាងក្រោមនេះ ៖

នៅក្រុងភ្នំពេញ ចំទន្លេចតុមុខ មានព្រះ..... ព្រះករុណាជាម្ចាស់ជីវិតលើត្បូងយ៉ាងរុងរឿង ។ ក្នុងព្រះបរមរាជវាំង មានព្រះរាជមន្ទីរជាច្រើនគឺ..... ខាងក្នុងព្រះទីនាំងទេវាវិនិច្ឆ័យមានព្រះ..... ដំកល់..... ប្រាំបួនជាន់ ។ នៅមុខព្រះបរមរាជវាំងខាងមាត់ទន្លេមាន

..... សម្រាប់ព្រះករុណា ស្ដេចយាងទៅគង់នៅក្នុងព្រះរាជពិធីបុណ្យអុំទូក (សំពះព្រះខែ) តាមទំនៀមទំលាប់ ។

## បង្រៀនមើល

## ទីក្រុងនិងស្រុកស្រែ

(សៀវភៅវិជ្ជាខេមរភាសា អាទិកដ្ឋាន ទំព័រ ៦៧)

ហាត់ភាសា ·— សំរិតទៅឯណា? — ត្រូវជាអ្វីនឹងគិម? គិមនៅឯណា? · សំរិតសរសេរសំបុត្រទៅគិមយ៉ាងណា? — អ្នកដែលឃើញពន្លឺភ្លើងអគ្គិសនីឬទេ? — ពន្លឺនោះយ៉ាងដូចម្ដេច? — គិមសរសេរសំបុត្រតបទៅសំរិតវិញថាយ៉ាងណា? — គិមថានឹងនាំសំរិតទៅបេះផ្លែឈើអ្វីខ្លះ? នឹងដើរទៅលេងនៅទីណា? — ព្រោះហេតុអ្វី? — អ្នកចូលចិត្តនៅទីក្រុងឬនៅស្រុកស្រែ? ហេតុអ្វី? ។

ការហាត់សរសេរ ·— សូមធ្វើតាមការហាត់ក្នុងមេរៀននេះ នៅទំព័រ ៦៨ ។

# សរសេរតាមសូត្រ

## ព្រះបរមរាជវាំង

នៅក្រុងភ្នំពេញ មានព្រះបរមរាជវាំងដ៏ថ្កើនរុងរឿងណាស់ មានកំពែងឥដ្ឋខ្ពស់ក្រាស់ព័ទ្ធជុំវិញ ខ្លោងទ្វារខាងកើតបែរចំទៅរកទន្លេចតុមុខ ៗ ក្នុងព្រះបរមរាជវាំង មានព្រះទីនាំងទេវាវិនិច្ឆ័យធំទូលាយដ៏ល្អស្ញប់ស្ញែង ដំបូលឡើងជាត្រួតមានរូបគ្រុឌទ្រ ខាងចុងកំពូលមានព្រះភក្ត្រព្រះព្រហ្មញញឹមទៅរកទិសទាំងបួន ហើយមានកំពូលត្រីសូលខ្ពស់ស្រួច ៗ ក្នុងព្រះទីនាំងទេវាវិនិច្ឆ័យ មានព្រះបល្ល័ង្ករាជ្យដ៏មានស្វេតច្ឆត្រប្រាំបួនជាន់គ្របពីលើ ៗ នៅកំពែងខាងក្នុងមានព្រះមហាប្រាសាទខេមរិន្ទ្រ ដែលជាដំណាក់សំរាប់ព្រះករុណា ជាម្ចាស់ជីវិតលើត្បូងគង់នៅ ៗ

សរសេរពាក្យពិបាក.– បរមរាជវាំង – ឥដ្ឋ – ព័ទ្ធ – ចតុមុខ – ព្រះភក្ត្រព្រហ្ម – ត្រីសូល – បល្ល័ង្ក – ស្វេតច្ឆត្រ – ស្ញប់ស្ញែង ៗ

# អក្សរផ្ចង់

ប ប ម ឃ ឋ

(សូមឲ្យធ្វើដូចអាទិត្យមុន)

# តែងសេចក្ដី

ចូរអ្នកសរសេរសំបុត្រមួយច្បាប់ផ្ញើទៅមិត្តសំឡាញ់អ្នកដែលនៅស្រុកស្រែ និយាយអំពីសេចក្ដីសប្បាយគ្រប់យ៉ាងឯទីក្រុង ។

– សេចក្ដីផ្ដើម:

– សេចក្ដីតបរៀប៖ អំពីពាំងហ្វូង-ផ្លូវថ្នល់-ផ្សារ-មន្ទីរផ្សេងៗ (ផ្ទះពេទ្យការ-សាលារៀន-ពេទ្យល្បាំ) ។

– សេចក្ដីបញ្ចប់៖ (ញុំាងមិត្តសំឡាញ់អ្នកឲ្យចង់ចូលទៅមើលទីក្រុង) ។

## បង្រៀនពាក្យ - ហាត់ភាសា

### អាទិត្យទី ៣.– ទីក្រុង (ត)

នាម.– ហាងទំនិញ ពាណិជ (អ្នកលក់ដូរ, អ្នកជំនួញ, ឈ្មួញ) អម្ពរពស្ត្រា (សំពត់) គន្ធពាណិជ (អ្នកជំនួញទឹកអប់) ពាណិជ្ជកម្ម (ការប្តូរអំពើលក់ដូរ, របរលក់ដូរ) ពាណិជ្ជការ (អ្នកធ្វើជំនួញ) ក្រសួងពាណិជ្ជការ (ក្រសួងត្រួតត្រាលើពួកអ្នកធ្វើជំនួញ) អាហារ = ចំណី, យាន = ទោចក្រ ត្រីចក្រ រថ រទេះ រថយន្ត កោងស៊ូ ឬកោងចក្រ, គោម ចង្កៀង ប្រទីប អគ្គិសនី ខ្សែលួសភ្លើង ម៉ាស៊ីនទឹក កប៉ាល់ ទូក នាវា កាណូត ថ្ងៃ ប៉ុកបាយ ។

គុណនាម.– ចំណេញ ខាត ក្រអូប ល្អ បរិបូណ៌ ឆ្ងាញ់ ប្រសើរ ថ្លៃ រហ័ស ឈ្មូធរ កកកុញ តានតាប់ ។

កិរិយាសព្ទ.– ទៅ មក ចេញ ចូល លក់ ទិញ តថ្លៃ ជិះ ដើរ បើក បរ ឆាក់ វិល បំភ្លឺ ទាញកញ្ចែ បត់ កាច់ចង្កូត បើកក្តោង ដឹកទំនិញ បញ្ជូន វាល់ ថ្លឹង សែង យួរ រែក ។

ការហាត់សរសេរ .- ចូរឆ្លើយតាមពាក្យចោទខាងក្រោមនេះ៖

អ្នកដែលទៅហាងទំនិញឬទេ ? - អ្នកត្រូវការទិញតែអ្វីខ្លះ ? -អ្នកជំនួញទឹកអប់ហៅថាអ្វី ? - ចុះអ្នកធ្វើជំនួញ ឬ ក្រសួងត្រួតត្រាលើពួកអ្នកធ្វើជំនួញហៅថាអ្វី ? - យានមានកង់ពីរហៅថាអ្វី ? - មានកង់បីហៅថាអ្វី? - បើគេដើរដំណើរតាមផ្លូវគោក គេប្រើយានអ្វីខ្លះ ? តាមផ្លូវទឹកគេប្រើយានអ្វីខ្លះ ?

## បង្រៀនមើល

## ចិននៅក្នុងប្រទេសឥណ្ឌូចិន

(សៀវភៅវិជ្ជាខេមរភាសាដដែល ទំព័រ ២០)

ហាត់ភាសា .- នៅប្រទេសឥណ្ឌូចិន មានជាតិដទៃអ្វីច្រើនជាងគេ ? - ចិនមកពីខេត្តណាខ្លះ ? - កូនចៅចិនដែលតាំងទីលំ-នៅខ្ជាប់ខ្លួនក្នុងប្រទេសឥណ្ឌូចិនហៅថាអ្វី ? ចិនមានចិត្តយ៉ាងណាក្នុងការរកស៊ី ? - ចិនដែលនៅស្រុកខ្មែរយូរមកហើយរកស៊ីអ្វី ? - ចិន

នៅក្រុងភ្នំពេញរកស៊ីអ្វី ? — ជាតិណាធ្វើជំនួញ ? — ការជំនួញរបស់ចិនបានចំរើនឬទេ ? — ប្រាក់ចំណេញចិនយកទៅណា ? — អ្នករាល់គ្នាត្រូវធ្វើដូចម្ដេច ដើម្បីចៀសវាងកុំឲ្យចិនបោកបាន ? ។

## សរសេរតាមសូត្រ

### អំពីផ្ទះលក់ទំនិញ

កាលពីថ្ងៃអាទិត្យមុននេះ ខ្ញុំជូនម្ដាយខ្ញុំទៅទិញសំពត់ព្រែនៅហាងលក់ទំនិញមួយខាងលិចផ្សារថ្មី ។ នៅក្នុងហាងនោះ ខ្ញុំឃើញគេដាក់ទូកញ្ចក់វែងភ្ជាប់ទៅជញ្ជាំងតាំងសងខាង, ជិតមាត់ទ្វារចូល មានតុមួយវែងសម្រាប់ទទួលប្រាក់ ក្នុងថ្នាក់ទូកញ្ចក់នីមួយ ៗ មានដាក់វត្ថុច្រើនយ៉ាងដូចជា មួក ឆត្រ ស្បែកជើង ទឹកអប់ សំពត់ព្រែលាតនិងព្រែផ្កាដ៏មានពណ៌ផ្សេងៗ ។ នៅមុខទូ ខ្ញុំឃើញមានចានគ្រប់យ៉ាង ពែងតូច-ធំ ហើយនឹងឆ្នាំងស្ពាន់-ដែក ។

សរសេរពាក្យពិបាក ៖ — កញ្ចក់-ភ្ជាប់-ជញ្ជាំង-ទ្វារ-តុ-វត្ថុ-ពណ៌-ស្ពាន់-ដែក ។

## តែងសេចក្ដី

ចូរអ្នកអធិប្បាយអំពីហាងបិទលក់ទំនិញមួយ ដែលអ្នកបានស្គាល់ជាប្រាកដ ៖

តើផ្ទះនោះសង់បែបដូចម្ដេច ? ធ្វើអំពីអ្វី ? - នៅក្នុងហាងនោះអ្នកឃើញមានទំនិញអ្វីខ្លះ ?- គេរៀបចំលក់បែបយ៉ាងណា ?- យោបល់យល់ឃើញរបស់អ្នកអំពីហាងបិទលក់ទំនិញនោះ ។

# កុមារដ្ឋាន

## រៀនពាក្យ - ហាត់ភាសា

### អាទិត្យទី ១. - អាហារ

បាយ, នំ, ផ្លែ, ត្រី, សាច់, សម្ល, ទឹកខ្ទះ, ទឹកត្រី, អំបិល, ប្រហុកៗ ដាំបាយ, ស្ល, ចៀន ។

ត្រូវបង្ហាញវត្ថុជាគ្រឿងអាហាររួចហើយទើបសួរ ។

ភាសា . – អ្នកស៊ីអ្វីសព្វថ្ងៃដើម្បីឲ្យជីវិតរស់នៅ ? (ចូរបណ្ដោយឲ្យឆ្លើយ = ខ្ញុំស៊ី...) ។ វត្ថុដែលអ្នកស៊ីទាំងប៉ុន្មានហៅអ្វី ? វត្ថុអ្វីដែលជាមេអាហារ ឬហៅអាហារជាប្រធាន ? ។ អាហារអ្វីខ្លះដែលជាអាហារផ្សំនឹងបាយ? អ្នកស្គាល់អាហារសត្វដែរឬអ្វី ? ។

ពាក្យរៀនក្នុងអាទិត្យ . – បាយដំណើប, បាយខ្សាយ, បបរ, សម្លទឹក, សម្លគោក, អន្លក់, ទឹកគ្រឿង, បន្លែ ។ សាច់គោ, សាច់ជ្រូក, មាន់, ទា, ក្ងាន, ត្រីស្រស់, ត្រីងៀត, អណ្ដើក, កន្ធាយ, ពងមាន់, ពងទា ។ ស្ពៃ, ផៃថាវ, ខ្ទឹម, គុយឆាយ, ម្ទេស, ឃ្លោក, ត្រឡាច, ននោង, ត្រកួន, ត្រកៀត ។ នំបុ័ង, អន្សម, នំកូរ, ក្រទាប ដំណាប់... ។

ជ្រាយ, ស្រួយ; កក, ត្រជាក់, សាប, ប្រៃ, ប្រហើរ, ក្រអូប, ឈ្ងុយ, ស្រស់, ក្រៀម, ជូរ, ឆៅ, ឆ្អិន, ផ្អែម, ឆ្ងាញ់, ល្វីង, ចត់, ហឹរ ... ។

ដាំបាយ, ចំហុយ, ស្ងោរ, ស្ល, អាំង, ចៀន, ឆា, ផ្សំគ្រឿង, បង់គ្រឿង, ចំអិន, ភ្លក្ស, ស៊ី, ហុត, ស្រូប, ទំពា, លេប... ។

## អាទិត្យទី២ · — វត្ថុសម្រាប់ផឹក

ទឹក, ទឹកទន្លេ, ទឹកបឹង, ទឹកអណ្ដូង, ទឹកស្រះ, ទឹកតែ, ទឹកដាំ ទឹកកាហ្វេ, ទឹកដំរង, ទឹកម៉ាស៊ីន, ស្រា, ទឹកភ្លៀង, ទឹកសមុទ្រ ។

សាប, ប្រៃ, ក្លៀវ, ស្អាត, កខ្វក់, ថ្លា, ល្អក់, ធ្អិន, ឆៅ, ក្ដៅ, ត្រជាក់ ខ្លាំង, ល្អ, សំពំង ។

ហូរ, រង, កក, ពុះ, ត្រង, ច្រោះ, ស្រវឹង, បង្កើតរោគ, បុះ, រាក, បុក, ផឹក, លាង, ងូត ..... ។

សូមឲ្យបង្ហាញទឹកល្អនិងទឹកអាក្រក់ឲ្យក្មេងស្គាល់ជាក់ រួចទើបប្រាប់ពីទឹកល្អនៅទីណា ទឹកអាក្រក់នៅទីណាតទៅទៀត ។ ឯវិធីបង្រៀនពាក្យ និងការសាស្រេចនឹងលោកគ្រូធ្វើចុះ ។

## អាទិត្យទី ៣·— ជម្ងឺ

គ្រុន, ផ្ដាសាយ, មួល, រាក, បុះ, ក្អួត, ប៉េស្ដ, បុកដោះ, សៀត, អសន្នរោគ, របេង, ឃ្លង់, ស្រែង, កមរមាស់, បូស, ដម្បៅ, អុត, កញ្ជ្រឹល, អុតស្វាយ, ឆ្កួតជ្រូក, ស្កន្ធ, ហើត, ប្រគ្រីវ, ឫសដូងបាត, ឫសដូងដុះ, លឿង, ពាប, រីងរៃ, ខ្វិន, ឈឺក្អក ។

គ្រុនខ្លាំង, មួលក្រហម, ស្រែងគគ្រាត, កមរលាយ, ខ្ទិនក្ង ។

ញាក់, រងា, កណ្ដាស់, ក្អក, ដុះ, នោម, ឈឺ, ចាប់, កើត, ស្រៀវស្រាញ, ក្រហាយ, រេះ, ប្រកាច់, អស់កម្លាំង, ធ្ងន់, ដរ, ពល, រគាំក្អក, ស្កន្ធជាង, ផ្សះ, ថែជម្ងឺ, ផឹកថ្នាំ, ពេទ្យមើល.....

ជម្ប្រាង .— ក្នុងបទបង្ហាត់ភាសា ត្រូវប្រើពាក្យទាំងនេះទៅភ្ជាប់បច្ច័យនឹងពាក្យ ចំណីអាហារ វត្ថុសំរាប់ផឹកដែលបង្រៀនហើយពីអាទិត្យមុន ៗ ៗ

## រៀនមើល-សរសេរ

អាទិត្យទី ១ .— មេរៀនទី ១០,១១ សៀវភៅកុមារដ្ឋាន ទំព័រ២២-២៥ ។

ឃ រ ល វ ស ហ ឡ អ

នឹងបង្រៀនអក្សរទាំងនេះ: សូមឲ្យប្រៀបធៀបនឹងតួអក្សរដែលបានរៀនហើយ ឃ ឃ ; វ អ ; រ វ ; ល ឈ ; ល ស; ហ ប ; ឡ ទ ។

## អាទិត្យទី ២ – មេរៀនទី ១២ ពីទំព័រ ២៦ . ២៩

### ព្យញ្ជនៈបន្ថែម

សូមឲ្យសរសេរនៅក្ដារខៀន ង ញ ប ម យ រ ល វ ស ហ អ ហើយប្រាប់ឲ្យយល់ថា អក្សរទាំងនេះ អក្សរនិមួយ ៗ មានសម្លេងប្ដូរសព្ទ ពីកាលណាគេថែមវណ្ណយុត្ដ " ឬ " ។ ង ង៉ ; ញ ញ៉ ; ប ប៉ ; ម ម៉ ; យ យ៉ ; រ រ៉ ; វ វ៉ ; ស ស៊ ; ហ ហ៊ ; អ អ៊ ។

សេចក្ដីចំណាំ - អក្សរ ណ ន ល មិនដែលមានវណ្ណយុត្ដិ មុសិកទន្ដ ត្រីសព្ទពីលើឡើយ គ្រាន់តែប្រែសម្លេងតាមសព្ទដែលបន្អោនមក ។

## អាទិត្យទី ៣ .– មេរៀនទី ១៣ – ទំព័រ ៣០

ស្រៈពេញតួ (សូមឲ្យរៀបធៀបនឹងស្រៈនិស្ស័យ)

## អាទិត្យទី ៤ .– មេរៀនទី ១៤ – ១៥ – ១៦ – ១៧ ១៨ ទំព័រពី ៣១ ទៅ ៣៩ ។

សូមយកតាមដំបូន្មានក្នុងសៀវភៅចុះ បើពាក្យណាដែលមាន

ចំនាស់នឹងសព្ទអាចឲ្យដកចោលដូចពាក្យ "គេច" — ពាក្យ "ចាហាន" មិនត្រូវមានត្រីសព្ទ ( ៊ ) ឡើយ ព្រោះទានាំមុខ ។

រៀនប្រកប (គ)

សូមធ្វើតាមរបៀបសៀវភៅតាំងពីមេរៀន ១៩ ទៅដល់ ២៣ គឺពីទំព័រ ៤០ ទៅដល់ ៤៩ ។

# បរិច្ឆណភ្ជាន

## រៀនពាក្យ — ហាត់ភាសា

### អាទិត្យទី ១.— ក្រុង

នាម.— ទីប្រជុំធំ, ក្រុង, មន្ទីររាជការ, ផ្លូវថ្នល់, បរិវេណ, ផ្សារ ។

គុណនាម.— កុះករ, ស្អាត, ស្កុកស្កក, ត្រង់, ទូលាយ, ឈូរឆ ។

កិរិយា.— ដើរលេង, ធ្វើការ, ជិះយាន ។

ភាសា.— ទីប្រជុំធំនៃស្រុកខ្មែរមានឈ្មោះហៅអ្វី ? ភ្នំពេញជាអ្វី ? ក្រុងនឹងភូមិមានសេចក្ដីប្លែកគ្នាយ៉ាងដូចម្ដេច ? អ្នកឃើញផ្ទះ

ក្នុងក្រុងយ៉ាងដូចម្ដេច ? ផ្លូវយ៉ាងដូចម្ដេច ? មនុស្សក្នុងទីក្រុងធ្វើការរកស៊ីដូចអ្នកស្រុកក្រៅដែរឬអ្វី ? ។

ពាក្យរៀន.— នាម.— ហាងជំនួញ, អ្នកជំនួញ, ឈ្មួញ, ទំនិញ, អ្នកលក់ដូរ, អ្នកពាណិជ្ជការ, រោងល្បាំ, វាំង, ប្រាសាទ, វត្ត, ផ្សារ, សួនច្បារ, ឃ្លាំងទំនិញ, ផ្ទះបង់ការប្រាក់, សាលារៀន, រោងទាហាន, យានជំនិះ, ពន្លឺអគ្គិសនី, ម៉ាស៊ីនទឹក, រោងជាង, កម្មករ ( ពួកអ្នកធ្វើជាងឬគូលី ) ។

គុណនាម.— រវាំរវៃ, កកកុញ, ខ្ពស់ត្រដែត, ធេងធាយ, ខ្វល, ក្រោងក្រោត, ត្រង់, ទូលាយ, ស្អាត, រុងរឿង ។

កិរិយា.— ជួញ, ដើរលេង, បញ្ជូន, ដឹក, លក់, ទិញ, តថ្លៃ ។

## រៀនមើល

១– ព្រះវិហារព្រះកែវ ( បរិច្ឆណដ្ឋានទំព័រ ១០៩-១១០ )

អានពាក្យ– មរកត ( មរកត់ )-ពន្រាយ ( ពណ្ណរាយ )-ដណ្ដើរ-ពេជ្រ-បល្ល័ង្ក ( ប៉ាល់ឡាំង ) ។

ពាក្យខុសត្រូវកែ ៖– ព្រះវិហារ កំពែងវាំង ត្បូង ពណ្ណរាយ ថ្ម ដំណើរ ១ រំពេច សង្ហា ពេជ្រ រតនបល្ល័ង្ក ។

ពាក្យពន្យល់និងពាក្យសួរ ៖– សូមឲ្យមើលក្នុងសៀវភៅចុះ ។

២– ជីតាខ្ញុំ (សៀវភៅដដែលទំព័រ ១៥)

៣– ជីដូនទីងទៅ (សៀវភៅដដែលទំព័រ ១៦)

ពាក្យត្រូវកែ = ដោយសារ វល្លិ ទៅហើយ និត្យនៅ ។

## សរសេរតាមសូត្រ

១– រឿងមើលទី ២– ដល់និទានរឿងព្រេងឲ្យយើងស្ដាប់

ពាក្យពិបាក ៖– អាយុ - ក៏ - ថ្ពាល់ - គាត់ - ទប់ ប្រត់ - ធ្វើការ ធ្ងន់– ទូន្មាន - បន្តិច - ពល់ - ស្ដាប់ ។

២– រឿងមើលទី ៣ – សង្កាត់ខាងដើមទំព័រ ១៦

៣– រឿងមើលទី ៣ (ត)

## តែងសេចក្តី

ចូរតែងប្រយោគជាមួយនឹងពាក្យនិមួយ ៗ ដូចមានខាងក្រោម=

ក្រុង , ផ្ទះជំនួញ , ផ្សារ , ទំនិញ , រថ ៗ

## មេសូត្ររត់មាត់

សេចក្តីកុកអន្ទូរ (បរិ. ទំព័រ ៤៨)

សូមកែពាក្យសួរជាសូ

សព្ទពាក្យ·- ផុះរៀប=ផុះមានរបៀប ។ មុខគួរ=គួរតែ ។ កុំឲ្យមានហ្មង=កុំឲ្យមានមន្ទិល ។

យោបល់របស់ខ្ញុំ·- គឺគេចង់ទូន្មានថា របស់ស្អាតត្រូវផ្សំនឹងរបស់ស្អាត ទើបបានសេចក្តីល្អ ។ រូបយើងស្អាត សំលៀកយើងក៏ត្រូវស្អាតដែរ ទីលំនៅក៏ត្រូវស្អាតដែរ ។ ខាងផ្លូវសេពគប់គឺអ្នកល្អសេពនឹងល្អ ។

# រៀនពាក្យ - ហាត់ភាសា

## អាទិត្យទី ២ .– ជំនួញ

**នាម** .– ហាងទំនិញ, ឃ្លាំងទំនិញ, ហាងមួក, ហាងដេរស្បែកជើង, ហាងទឹកអប់, ហាងប្រទីប, ហាងគ្រឿងចក្រ, ហាងគ្រឿងការី, ហាងសំពត់, ហាងក្រដាស, ឃ្លាំងអង្ករ, ឃ្លាំងប្រេង, ឃ្លាំងលោហធាតុ, ឃ្លាំងស្រូវ, រោងពុម្ព, រោងយន្ត, រោងជាង ។ អ្នកជំនួញ, អ្នកទទួលម៉ៅ, អ្នកទិញ, ថៅកែ, មេហាង, កូនឈ្នួល, កញ្ចក់, ហិប, ទ្យាំង ។

**គុណនាម** .– ល្អ, ប្រសើរ, ស៊ីអរ, រីករាយ, ព្រោងព្រាត, ថ្មី, ចាស់, ថ្លៃថោក, គ្រឹកគ្រាក់ ។

**កិរិយា** .– ទិញ, លក់, តថ្លៃ, កាត់ថ្លៃ, ឡើងថ្លៃ, ជញ្ជូន, ដឹកនាំ, បញ្ជូន, រៀប, គរ, លី, សែង, អូស, កណ្ដៀត, ទូល, រែក ។

## រៀនមើល

១ - ត្រូវមានសេចក្ដីគួរសមដល់មនុស្សពិការ (ទំព័រ ២៩)

សុំឲ្យកែដំរូវ — គួរសម, អាទិត្យ, កិរិយា ។

២ . សេចក្ដីកោតខ្លាចចាស់ព្រឹទ្ធាចារ្យ (ទំព័រ ៥៥)

សុំឲ្យកែដំរូវ- ព្រឹទ្ធាចារ្យ, ពិសា ។

សព្ទពាក្យ .— ចាស់ព្រឹទ្ធាចារ្យ គឺចាស់ដែលគេតែងគោរព

៣ — ចូរកុំចំអកឡកឡឺយដល់មនុស្សពិការ (ធម្មក្រិ . ទំព័រ ៥៤)

## សរសេរតាមសូត្រ

១ — រៀនមើលទី ១ សង្កាត់ខាងដើម (ទំព័រ ២៩)

ពាក្យពិបាក .— គួរសម - មនុស្ស - ពិការ - អាទិត្យ - កុមារ - អាយុ - មុខ - ទ្វារ - ភូមិ - ដើរ - ត្រដរ - ក៏ ។

២ — រៀនមើលទី ១ សង្កាត់ទី ២

ពាក្យពិបាក .- បន្ទោស, ដូច្នេះ, ចិត្ត, មេត្តា, ខុស, ដូច្នោះ ៗ

៣ - រៀនមើលទី ២ សង្កាត់ខាងដើម (ទំព័រ ៥៥ )

ពាក្យពិបាក .- ខាប, ព្រឹទ្ធាចារ្យ, កាហារ, សិស្ស-អង្គុយ បរិភោគ- កន្លែង - ប៉ុន្មាន ៗ

## តែងសេចក្ដី

សុំឲ្យគ្រូរើសពាក្យប្រាំឬប្រាំមួយមាត់ ហើយឲ្យសិស្សធ្វើប្រយោគ មួយ ៗ ជាមួយនឹងពាក្យមួយ ៗ ដូចអាទិត្យមុន ៗ

## រៀនពាក្យ- ហាត់ភាសា

### អាទិត្យទី ៣ និងទី ៤ .- យានជំនិះ

នាម .- រថ , រទេះសេះ , រទេះគោ, រទេះឡាន (រថយន្ត) រថសងម៉ា (រថសេះពីរ), ត្រីចក្រ (កង់បី), ទោចក្រ (កង់ពីរ)

រថទូ, - រថផ្លិតកង់ពីរ, ម៉ូតូស៊ីក្លូ, កប៉ាល់, កាណូត, ទូកដ, ទូកថ្ង, ទូកប៉ុកចាយ, ទូកកៃហៅ, យន្តហោះ, ម៉ាស៊ីន, កំពង់, ផែ, ស្ពាន, កប៉ាល់

គុណនាម ៈ– លឿន រហ័ស ប្រុងប្រាង ស្អកស្កាស ត្រៀបត្រា បង្គ្រឹង ។

កិរិយា .– បររទេះ, ឡើងចុះ, ផ្ទុក, បើក, បត, ចេញ, ចូល ត្រួតត្រា, ចំឡង, បែរ, អុំ, ហៅ ។

## រៀនមើល

១– សេចក្ដីប្រព្រឹត្តនិងជីតាជីដូន (ធម្មក្រិ - ទំព័រ ១៩)

សុំឲ្យកែពាក្យ · – សេចក្ដីប្រព្រឹត្ត (នាម) ប្រព្រឹត្ត (កិរិយា) និង-ទឹក ។

២- ជីដូនសប្បាយចិត្តនឹងចៅប្រតិបត្តិ (ធម្មក្រិ. ទំព័រ ២១)

សុំឲ្យកែពាក្យ - ប្រតិបត្តិ ឬបដិបត្តិ - ពាក្យ ។

## សរសេរតាមសូត្របញ្ជាក់

ឲ្យយករឿងមើលមកធ្វើវិធីសរសេរតាមសូត្រចំនួន ៥ ឬ ៦ បន្ទាត់ ហើយឲ្យហាត់សរសេរពាក្យពិបាកជាមុនដូចធម្មតា ។

# ឧត្តមដ្ឋាន និង មជ្ឈិមដ្ឋាន ទី២

## នព្វន្ត

### អាទិត្យទី ១.— អំពីលេខភាគ

បើយើងយកក្រដាសច្រើនសន្លឹកទំហំប៉ុនគ្នា មកបែងក្នុងសន្លឹកនិមួយ ៗ ជា ៨ភាគស្មើគ្នា ហើយយើងយក

ក.— បីភាគមករួមជាមួយគ្នា នោះយើងបានក្រដាស ៣ ក្នុងភាគ ៨ យើងសរសេរដូច្នេះ $\frac{៣}{៨}$ ។

ខ.— ១១ ភាគមករួមជាមួយគ្នា នោះយើងបានក្រដាស ១១ ក្នុងភាគ ៨ យើងសរសេរដូច្នេះ $\frac{១១}{៨}$ ។

$\frac{៣}{៨}$ និង $\frac{១១}{៨}$ ជាចំនួនលេខភាគ ។

ចំនួន ៣ និងចំនួន ១១ ហៅថាភាគដែលត្រូវយក ចំនួន៨ខាងក្រោមហៅថាភាគដែលចែក ។ គេសរសេរភាគដែលត្រូវយកខាងលើភាគដែលចែកខាងក្រោម ខណ្ឌគ្នានិងបន្ទាត់ផ្តេកមួយ ។

គេត្រូវមើលភាគដែលត្រូវយកមុន រួចមើលភាគដែលចែកទៀត ដូចជា៖ $\frac{៣}{៨}$ ត្រូវមើលថា ៣ ក្នុងភាគ ៨ ។

ឯចំនួន $\frac{១}{២}$ ត្រូវមើលថាពាក់កណ្តាលក៏បាន ។

ការហាត់ .— ចូរមើលចំនួនខាងក្រោមនេះ ៖

$\frac{៥}{៧}$ $\frac{៩}{៤}$ $\frac{៧}{១០}$ $\frac{៤០}{១៧}$ $\frac{៤}{៣}$ $\frac{១}{២}$ $\frac{៥}{៦}$ $\frac{៣}{២}$ ។

ចូរមើលចំនួនខាងក្រោមនេះ តើត្រូវជាប៉ុន្មានភាគក្នុង ១ ម៉ែត្រ ៖ ៧ ដម.— ៣៥ សម. — ១៤ដម — ៧១៥ សម. ។ ៣៥៦មម. ។

ការហាត់សរសេរ .— ចូរសរសេរចំនួនខាងក្រោមនេះ រើដាក់ពីធំទៅតូចពីឆ្វេងទៅស្តាំ ។

$\frac{៧}{១៥}$ $\frac{៤}{១៥}$ $\frac{១៩}{១៥}$ $\frac{២}{១៥}$ $\frac{១២}{១៥}$ $\frac{១}{១៥}$ ។

ប្រេងកាត ១ លីត្រថ្លៃ ៥រ,៥០ ប្រេងកាត $\frac{១}{៤}$ ក្នុង ១ លីត្រ ថ្លៃប៉ុន្មានរៀល? $\frac{៧}{៤}$ ក្នុង ១ លីត្រថ្លៃប៉ុន្មានរៀល ? ។

អាទិត្យទី ២ .— ចំនួនភាគធៀបនឹងចំនួនភាគ ។

លេខភាគធៀបនឹងចំនួនគត់ឬចំនួនជុំ ។

ឧទាហរណ៍ ៖– ប្រវែងវត្ថុ ១ បើគេយក

ក – $\frac{៣}{៣}$ $\frac{៤}{៤}$ $\frac{៥}{៥}$ គេនឹងបានប្រវែងស្មើនឹងវត្ថុនោះទាំងអស់ឬទាំងដុំ ។

ខ – $\frac{៤}{៣}$ $\frac{៧}{៦}$ $\frac{៩}{៥}$ គេនឹងបានប្រវែងច្រើនលើសអំពីប្រវែងវត្ថុនោះ ។

គ – $\frac{២}{៣}$ $\frac{១}{៤}$ $\frac{៣}{៤}$ គេនឹងបានប្រវែងថយចុះតិចជាងប្រវែងវត្ថុនោះ ។

ដូច្នេះ បើកាលណាចំនួនភាគដែលត្រូវយក

ក – $\frac{៧}{៧}$ ស្មើនឹងភាគដែលចែក លេខភាគនោះស្មើនឹងចំនួនដុំ ។

ខ – $\frac{២}{៩}$ តិចជាងភាគដែលចែក លេខភាគនោះតូចជាងចំនួនដុំ ។

គ – $\frac{៥}{៤}$ ធំជាងភាគដែលត្រូវចែក លេខភាគនោះច្រើនជាងឬធំជាងចំនួនដុំ ។

លេខភាគពីរ $\frac{៥}{១២}$, $\frac{៧}{១២}$ មានចំនួនភាគដែលចែកដូចគ្នា ចំនួនភាគដែលធំនោះ គឺចំនួនដែលមានភាគត្រូវយកធំឬច្រើនជាងគេ៖

$$\frac{៧}{១២} \text{ ធំជាង } \frac{៥}{១២}$$

លេខភាគពីរ $\frac{៥}{៧}$ នឹង $\frac{៥}{៩}$ មានចំនួនភាគដែលត្រូវយកប៉ុនគ្នា លេខភាគធំជាងគេនោះ គឺចំនួនមានភាគដែលចែកនោះតិចជាងគេ ៖ ។

$$\frac{៥}{៧} \text{ ធំជាង } \frac{៥}{៩}$$

**ការហាត់** ៈ– ចូររកលេខភាគណាដែលធំជាងគេ៖

$\frac{៣}{៨}$ និង $\frac{៥}{៨}$, $\frac{៧}{៣}$ និង $\frac{៧}{៤}$ ។

ចូររើសលេខភាគខាងក្រោមនេះដាក់ជាពីរចំណែក ១ ចំណែកធំជាងចំនួនដុំ ១ចំណែកទៀតតូចជាងចំនួនដុំ៖ $\frac{៥}{៨}$ $\frac{៨}{៧}$ $\frac{៥}{៦}$ $\frac{២}{៥}$ $\frac{១១}{១០}$ $\frac{៦}{៥}$ $\frac{៨}{៩}$ $\frac{៣}{៤}$ $\frac{១៣}{១៥}$ $\frac{១១}{៩}$ ។

## អាទិត្យទី ៣ ៈ– ការហាត់គិតមាត់ទទេ

អំពីចែកចំនួននឹង ២-៣-៩-៥-៤ ។

ចំនួនណាមានលេខ ( ០-២-៤-៦ និង ៨ ) នៅខាងចុង ចំនួននោះចែកនឹង ២ ដាច់ ។ ៤០: ២=២០ ។

ចំនួនណាមាន ( ០ ឬ ៥ ) នៅខាងចុង ចំនួននោះចែកនឹង ៥ ដាច់៖ ៣៥: ៥= ៧ ។

ឯចំនួនដែលចែកនឹង ៣ ឬនឹង ៩ ដាច់នោះ គឺចំនួនណាដែលគេបូករួមលេខគ្រប់ខ្ទង់ទាំងអស់ទៅ ឃើញបានចំនួនចែកនឹង ៣ ឬនឹង៩ដាច់ ។

ឧបមា៖ ១៧៨៥ ( ១+៧+៨+៥=២១ ) ២១ ចែកនឹង ៣ ដាច់ ។

២៣៩៦៧ (២+៣+៩+៦+៧=២៧) ២៧ ចែកនឹង ៣ ឬនឹង ៩ ដាច់ ។

ចំនួនណាមានសូន្យ ២ ខ្ទង់នៅខាងចុងឬលេខពីរខ្ទង់ខាងចុងចែកនឹង ៤ ដាច់ ។

ឧបមា៖ ២១៦ ចែកនឹង ៤ ដាច់ ព្រោះលេខពីរខ្ទង់ខាងចុង ១៦ ចែកនឹង ៤ សេសសូន្យ ។

អាទិត្យទី ៤ .– រៀនសាឡើងវិញ ។

## រង្វាស់រង្វាល់

អាទិត្យទី ១ .– អំពីហិកតារ អារ នឹង សង្ទីអារឬសង់ចារ ។

នឹងវាស់ទំហំដីស្រែចំការ គេប្រើខ្នាតមួយជាប្រធានហៅ "អារ" ។ គេនិយាយថា ស្រែនេះ ចំការនេះ ទំហំ ១០ អារ, ២៥ អារ, ៦០ អារ ។ល។ គឺ ១ អារ មាន ១ ដាម$^{២}$ ឬ ១០០ ម$^{២}$ ។

រង្វាស់ដែលធំជាងអារគឺ "ហិកតារ" មាន ១០០អារ ឬ ១០.០០០ម$^{២}$ ។

រង្វាស់ដែលតូចជាងអារគឺ "សង់ចារ" មាន ១ ម$^{២}$ ។

១ សង់ចារតូចជាងអារ ១០០ ដង ឬ ..... ១ ម៉ែត្រក្រឡា ។

១ អារមាន ១០០ ម$^{២}$ ឬ ...... ១ ដាម$^{២}$ ។

១ ហិកតារមាន ១០០ អារឬ ១០.០០០ ម$^{២}$ ឬ... ១ ហិកតូម៉ែត្រក្រឡា ។

នឹងមើលឬនឹងសរសេរចំនួន អារ ហិកតារ ឬសង់ទារ គេមើលឬសរសេរដូចជាចំនួនជាម៉ែត្រក្រឡា ដែលយើងបានឃើញរួចហើយពីខាងមុន គឺនៅខ្ទង់នីមួយៗមានលេខ២តួ ៗ

ដូចជា៖ ៦៤៣ អារ ២៨ ត្រូវមើលថា ៦៤៣ អារ ២៨ សង់ទារ ឬ ៦ ហិកតារ ៤៣ អារ ២៨ សង់ទារ ។

១២ហិកតារ ៦០៤៣ ត្រូវមើលថា ១២ ហិកតារ ៦០៤៣ សង់ទារ ឬ ១២ ហិកតារ ៦០ អារ ៤៣ សង់ទារ ។

ការហាត់ ។— ចូរមើលចំនួនខាងក្រោមនេះ កាត់ជាខ្ទង់ ៗ ៖

៦.៥៤អារ ។ ៩ ហិកតារ ៣៧ ។ ១៣ អារ ៤ ។ ៣៨០៤៣ សង់ទារ ។ ៥ ហិកតារ ៧៩០៦ ។ ២០៤៨ អារ ៧ ។ ០ ហិកតារ ០៨៤ ។

ចូរមើលចំនួនខាងលើនេះជាម៉ែត្រក្រឡាវិញ ។

ចំណោទ ។— ស្រែ ៤ ជ្រុងស្មើមួយប្រវែងបរិវេណ ៨០០ ម៖ ថ្លៃ ១២០០ រៀល តើដីស្រែនេះក្នុង ១ ហិកតាថ្លៃប៉ុន្មាន? ។

ចូររកថ្លៃបំគារមួយកង ៤ ជ្រុងទ្រវែង ទទឹង ៦៨០ម៉ែត្រ បណ្ដោយ ៣៨ដាម ៦ ហើយថ្លៃ ៣៤០ រៀលមួយអារ ។

# ធរណីមាត្រសាស្ត្រ

## អាទិត្យទី ១ .– អំពីត្រីកោណ

គ្រូគូរត្រីកោណនៅក្ដារខៀនឲ្យសិស្សពិនិត្យមើលជ្រុងនឹងមុម រួចឲ្យរកន័យ ។ ដែលហៅថាត្រីកោណគឺជាផ្ទៃមាន ៣ ជ្រុង ហើយមានមុម៣ដែរ ។




ដូចជាផ្ទៃ កខគ នេះជាត្រីកោណ ។ កខ ជាជ្រុងទី ១, បន្ទាត់ ខគ ជាជ្រុងទី ២, បន្ទាត់ គក ជាជ្រុងទី ៣ ។ ឲ្យសិស្សគូរត្រីកោណនៅក្ដារឆ្នួន ។




អំពីបាតត្រីកោណ .– ឲ្យសិស្សពិនិត្យមើលត្រីកោណមានជ្រុង ៣ ជ្រុងណាមួយយកធ្វើជាបាតក៏បាន តែតាមធម្មតាគេយកជ្រុងដែលវែងជាងគេធ្វើជាបាតត្រីកោណ កគ ជាបាតត្រីកោណ កខគ ។

កំពស់ត្រីកោណ .– បន្ទាត់ ខឃ សំយុងចុះពីកំពូល ខ ចំមកលើបន្ទាត់ កគ ជាកំពស់ត្រីកោណ កខគ ។

ការហាត់ .- ឲ្យគូរត្រីកោណកំពស់ ៧ សម. បាតប្រវែង ៥ សម ។

អាទិត្យទី ២._ ការរកផ្ទៃត្រីកោណ ។

សូមគ្រូយកក្រដាសមួយសន្លឹកមានរាងជា ៤ ជ្រុងទ្រេតស្រប ក ខ គ ឃ យកកន្ត្រៃកាត់ជា ២ ភាគស្មើគ្នាតាមមុម ខ កាត់ទៅកំពូល ឃ បានជាត្រីកោណពីរទំហំប៉ុនគ្នា ដូច្នេះ ឃើញថាផ្ទៃត្រីកោណ គឺពាក់កណ្ដាលផ្ទៃ ៤ ជ្រុងទ្រេតស្រប ដែលមានកំពស់នឹងបាតប្រវែងគ្នា ។ យើងបាន




ឃើញថារកផ្ទៃ ៤ ជ្រុងទ្រេតស្របត្រូវយក ។

បាត × កំពស់ =

ឯផ្ទៃត្រីកោណគឺពាក់កណ្ដាលផ្ទៃ ៤ ជ្រុងទ្រេតស្រប ត្រូវយក

$$\frac{\text{បាត} \times \text{កំពស់}}{២} =$$

បើត្រីកោណមួយកំពស់ ៥ ម. បាត ៨ ម. នេះមានផ្ទៃតែពាក់

កណ្ដាល (៥ × ៨) គឺ ២០ ម$^{២}$ ឬ យកតែពាក់កណ្ដាលកំពស់ គុណនឹងបាត ឬ ពាក់កណ្ដាលបាតគុណនឹងកំពស់ ក៏ឃើញដូចគ្នា ។

$$\text{ផ្ទៃ} = \frac{\text{ប} \times \text{ក}}{២} =$$

$$\text{ផ្ទៃ} = \text{ប} \times \frac{\text{ក}}{២} =$$

$$\text{ផ្ទៃ} = \frac{\text{ប}}{២} \times \text{ក} =$$

ឧបមា.— ត្រីកោណមួយ បាតប្រវែង ១០ម កំពស់ ៦ម. តើផ្ទៃត្រីកោណនេះទំហំប៉ុន្មានម៉ែត្រក្រឡា? ។




ត្រូវយក $\frac{១០\text{ម} \times ៦}{២} = ៣០\ \text{ម}^{២}$

ឬ $\frac{១០}{២} \times ៦ = ៣០\ \text{ម}^{២}$

ឬ $១០ \times \frac{៦}{២} = ៣០\ \text{ម}^{២}$

នឹងរកប្រវែងបាត ត្រូវយកផ្ទៃចែកនឹងពាក់កណ្ដាលកំពស់ $៣០ : \frac{៦}{២} = ១០\text{ម}$

នឹងរកប្រវែងកំពស់ត្រូវយកផ្ទៃចែកនឹងពាក់កណ្ដាលបាត $៣០ : \frac{១០}{២} = ៦\text{ម}$

ការហាត់ .— ស្រែមួយរាងត្រីកោណកំពស់ ៧ម បាត ១៨ម តើទំហំប៉ុន្មានម៉ែត្រក្រឡា?ៗ បើកំពស់ ៦ម បាត ២៤ម តើផ្ទៃប៉ុន្មានម៉ែត្រក្រឡា?ៗ

ចំណោទ .— សួនមួយរាងជាត្រីកោណកំពស់ ២៩ម បាត ៣៨ម តើសួននោះទំហំប៉ុន្មានអារ? ។

ចំការត្រីកោណ ១ កំពស់ ២០ម បាតប្រវែង ៤០ ម៉ែត្រ ហើយនឹងចំការ ៤ ជ្រុងទ្រវែងមួយ ទទឹង ៣០ម បណ្ដោយ ៥០ ម៉ែត្រ ។ តើចំការណាធំជាងចំការណាប៉ុន្មាន? ។

## អាទិត្យទី ៣ .— ចតុរ័ង្សព្នាយស្របមានជ្រុងស្មើ ៗ

ប្រដាប់ដែលត្រូវយកមកបង្រៀន៖ ក្រដាសក្រាស ក្រដាសពណ៌ កន្ត្រៃ កែង ទូរដេស៊ីម៉ែត្រ បន្ទាត់ ។

របៀបបង្រៀន.— សូមគ្រូយកក្រដាសមួយសន្លឹករាង ៤ ជ្រុងទ្រវែងមកបត់ជា ៤ ភាគតាមផ្នត់ ក គ បានជាបន្ទាត់បណ្ដោយ (ប) រួចបត់តាមផ្នត់ ខ ឃ ទៀត បានជាបន្ទាត់ទទឹង (ទ) ហើយយកបន្ទាត់គូសភ្ជាប់ពី ក ទៅ ខ ពី ខ ទៅ គ ពី គ ទៅ ឃ ពី ឃ ទៅ ក វិញ ដូចគំរូ



ខាងលើនេះ យើងបានជាចតុរង្សមួយផ្សេងមានរាង៤ជ្រុងដែរ ។ ចតុរង្សថ្មីនេះមានជ្រុងទាំង៤ប្រវែងគ្នា ហើយស្របគ្នាពីរៗ មានមុមប៉ុនគ្នាពីរៗ ដែរ សូមបញ្ជាក់សិស្សថា ៖

| | | | |
|---|---|---|---|
| កខ | ប្រវែងគ្នាហើយស្របគ្នានឹង | | ឃគ |
| ខគ | " | | កឃ |
| មុម ខ | ប៉ុនមុម | | ឃ |
| " ក | " | | គ |

អំពីរកផ្ទៃចតុរង្សព្នាយស្រប .— សូមគ្រូយកកន្ត្រៃកាត់ផ្ទៃដែលបានធ្វើឲ្យសិស្សមើលខាងលើនេះ តាមជ្រុង កខ ខគ គឃ ឃក យើងបានជាត្រីកោណស្វាបក្ដោងតូចៗបួនប៉ុនគ្នា ហើយយកត្រីកោណទាំង៤នេះទៅដាក់ផ្គុំត្រួតពីលើចតុរង្សដែលសល់ពីកាត់ ឃើញបានទំហំប៉ុនគ្នា ដូច្នេះផ្ទៃចតុរង្សព្នាយស្របគឺបាន់ផ្ទៃ៤ជ្រុងទ្រវែងពាក់កណ្ដាលគឺ

$$\frac{ប \times ទ}{២} = ផ្ទៃ\ (ផ្ទ)$$

បើរកបណ្ដោយ $ប = ផ្ទ : \frac{ទ}{២} =$

" ទទឹង $ទ = ផ្ទ : \frac{ប}{២} =$

ការហាត់ .– ឲ្យគាត់ក្រដាសពណ៌ជាចតុរង្សព្នាយស្របបណ្តោយ ១០សម. ទទឹង៥ សម.ហើយកាត់ផ្ទៃនេះផ្គុំជាផ្ទៃ៤ជ្រុងទ្រវែងវិញ ។

បំណោទ .– គេទិញស្រែមួយរាងជាចតុរង្សព្នាយស្របមានជ្រុងស្មើ ប្រវែងបណ្តោយ៥៧ម. ទទឹងប្រវែង៤៣ម. ថ្លៃ៨៧៥រៀល ។ តើស្រែនោះថ្លៃមួយម៉ែត្រក្រឡាប៉ុន្មានរៀល ? ។

## គណិតផ្ទាល់

ឥព្វ ៨១

### អាទិត្យទី ១– លេខគុណ

សូមសាបស្រៀនមេលេខគុណ ៦-៧-៨-៩ នឹង ១០ ឲ្យសិស្សសូត្រមេលេខគុណដែលបានដាក់ឲ្យរៀនទាំងប៉ុន្មាន ឲ្យសូត្រហើយសួរតោទផង ។ ឧបមា៖ ដូចថាត្រូវជាប៉ុន្មាន ៩ បួនដង? ។ ល ។ សួរដូច្នេះហើយត្រូវសួរជាចំណោទវិញ ។

ឧបមា៖ ខ្ញុំទិញក្រូចថ្លុង ៧ មួយថ្លៃ ៦ កាក់ នោះខ្ញុំត្រូវឲ្យលុយទៅគេប៉ុន្មាន ?

-លេខគុណ ៥ នឹង ៦ ( មើលសៀវភៅនព្វន្តទំព័រ ៣៣-៣៤)

-លេខគុណ ៧ នឹង ៨ ( មើលសៀវភៅទំព័រ ៤៤-៤៥)

-លេខគុណ ៩ នឹង ១០ ( មើលសៀវភៅទំព័រ ៤៦ - ៤៧)

វិធីហាត់មាត់ទទេនឹងហាត់សរសេរ ៖— សូមជ្រើសរើសគេ វិធីតាំងប៉ុន្មាន ដែលមានក្នុងសៀវភៅនៅទំព័រ ដែលមានខាងលើស្រាប់ ដាក់ឲ្យសិស្សធ្វើផងចុះ ។

អាទិត្យទី ២ .— លេខគុណ ចែក នឹង ២ ៤ ២០ ៤០ ។

នឹងគុណ ឬ ចែកលេខឆាប់ត្រូវធ្វើដូចរបៀបនេះ ៖

គុណនឹង ២ .— ៥៧ × ២ គឺ ៥៧ + ៥៧= ១១៤

ចែកនឹង ២ .— នឹងចែកចំនួននឹង ២ គេត្រូវយកពាក់កណ្ដាលចំនួននោះ ។

៣០ : ២ គឺពាក់កណ្ដាល ៣០ មាន ១៥ ។

ចែកនឹង ៤ .— ចែកចំនួននឹង ៤ គេត្រូវយកពាក់កណ្ដាលចំនួននោះ ទើបគេយកពាក់កណ្ដាលចំនួនដែលគេរកឃើញ គឺ: ៣៦: ៤= ពាក់កណ្ដាល ៣៦ មាន ១៨ ពាក់កណ្ដាល ១៨ មាន ៩ គេឃើញ ៣៦:៤=៩

គុណនឹង ២០-៤០ .— នឹងគុណចំនួននីមួយៗ នឹង ២០ ឬ ៤០ គេត្រូវគុណនឹង ២ ឬនឹង ៤ រួចគេបន្ថែមសូន្យមួយពីខាងស្ដាំចំនួនដែលឃើញនោះ ។

ឧបមាៈ ១៥ × ២០ គឺ ១៥ × ២ = ៣០ ថែមសូន្យ ១ ពីខាងស្តាំត្រូវជា ៣០០ .

១៥ × ៤០ = ១៥ × ៤ = ៦០ ថែមសូន្យ ១ ពីខាងស្តាំ ៦០ ត្រូវជា ៦០០ ។

លេខចែកនឹង ២០– ៤០– នឹងចែកចំនួនអ្វីមួយ នឹង ២០ ឬ ៤០ គេត្រូវចែកចំនួននោះនឹង ១០ ទើបគេយកពាក់កណ្តាល ឬ យកភាគបួនចំនួនដែលគេឃើញ ៖

ឧបមាៈ ៦០ : ២០ = ៦០ : ១០ = ៦ ពាក់កណ្តាល ៦ គឺ ៣; ៦០ : ២០ = ៣, ។

៨០ = ៤០ = ៨០ = ១០ = ៨ ភាគបួននៃ ៨មាន ២; ៨០ : ៤០ = ២

### វិធីហាត់នឹងការចែក .– ត្រូវជាប៉ុន្មាន

៦០, ២៨, ៣២, ៥៨, គុណនឹង ២?

– ២៥, ៧៥, ៥០, ៣៥, គុណនឹង ៨?

– ៣០០, ៧៥០, ៦២២, គុណនឹង ២០?

– ១៦០, ២៤៨, ៣៣៦, ៧៩២ គុណនឹង៤០?

ត្រូវបានចំនួន ៣០ , ៦៤ , ១៤០ , ២៣៦ ចែកនឹង ២

– ៣៦ , ៨៤ , ១២៤ , ៨៣៦ – ៤

– ៦០ , ១៤០ , ២៦០ , ៨២០ – ២០

– ៨០ , ១២០ , ៣៦០ , ៩២០ – ៤០

**វិធីហាត់សរសេរ** ៖– សូមរកចំណោទដាក់ឲ្យសិស្សធ្វើផងចុះ

**អាទិត្យទី ៣** .– លេខគុណនឹងចែក (ត)

គុណឬចែកនឹង ៥ – ២៥

**គុណនឹង ៥** .– នឹងគុណចំនួនអ្វីនឹង ៥ គេត្រូវគុណចំនួននោះនឹង ១០ ទើបគេយកពាក់កណ្ដាល ចំនួនដែលគេឃើញនោះគឺ ៖

២៥ × ៥ = ២៥ × ១០ = ២៥០ ពាក់កណ្ដាល ២៥០ គឺ ១២៥ ។

**ចែកនឹង ៥** .– នឹងចែកចំនួនមួយ ៗ នឹង ៥ គេចែកនឹង ១០ ទើបគេយកចំនួនដែលគេឃើញ ទៅគុណនឹង ២ ។

២៥ : ៥ = ២៥ : ១០ = ២,៥០ × ២ = ៥

**គុណនឹង ២៥** .– នឹងគុណចំនួនអ្វីមួយនឹង ២៥ គេគុណនឹង ១០០ ទើបយកភាគបួនចំនួនដែលឃើញ នោះគឺ ៖

១៣ × ២៥ = ១៣ × ១០០ = ១៣០០ ភាគបួន ១៣០០ គឺ ៣២៥ ។

ចែកនឹង ២៥ .– ដើម្បីចែកចំនួនមួយនឹង ២៥, គេគុណវានឹង ៤ ហើយគេចែកនឹង ១០០ ។ ឧបមា៖ ៤០០ : ២៥ = ៤០០ × ៤ = ១៦០០ : ១០០ = ១៦. ។

## រង្វាស់រង្វាល់

អាទិត្យទី១ .– អំពីហិកតូម៉ែត្រ

យើងបានដឹងចាំពីអស់គ្នាមករួចហើយ ថារង្វាស់ប្រវែង ១០ម៉ែត្រ គេឲ្យឈ្មោះថា ១ដេកាម៉ែត្រ ប៉ុន្តែឥឡូវនេះ មានរង្វាស់មួយទៀត វែងជាងរង្វាស់ដេកាម៉ែត្រ ១០ ដងទៀត រង្វាស់នេះគឺ គេឲ្យឈ្មោះហិកតូម៉ែត្រ រង្វាស់នេះពុំមែនជារង្វាស់ដែលមានរូបជាក់ស្តែងដូចជារង្វាស់ម៉ែត្រនិងដេកាម៉ែត្រនោះទេ គឺគ្រាន់តែមានឈ្មោះសំគាល់ថាជារង្វាស់មានប្រវែង ១០០ម៉ែត្រប៉ុណ្ណឹង ពីព្រោះគេមិនហៅថា ១០០ ម៉ែត្រ ២០០ ម៉ែត្រ ៣០០ ម៉ែត្រទេ ។ គេហៅថា ១ ហិកតូម៉ែត្រ, ២ ហិកតូម៉ែត្រ

៣ ហិកតូម៉ែត្រ គេសរសេរកាត់យ៉ាងដូច្នេះ ហ.ម ។ ឧបមា: ៧ ហិកតូម៉ែត្រ= ៧ ហម ។ ៣ ហិកតូម៉ែត្រ =៣ ហ.ម ។

$៨៤៧^{\text{ម}} = ៨០០^{\text{ម}} + ៤០^{\text{ម}} + ៧^{\text{ម}}$ ឬ $៨^{\text{ហ.ម}} + ៤^{\text{ដា.ម}} + ៧^{\text{ម}}$; $៥៨៦^{\text{ម}} = ៥^{\text{ហ.ម}} + ៨^{\text{ដា.ម}} + ៦^{\text{ម}} =$

ហាត់គិតមាត់ទទេ — វង្វាស់ ១០ ម៉ែត្រគេឲ្យឈ្មោះថាអ្វី ? វង្វាស់ប្រវែង ១០ ដេកាម៉ែត្រឈ្មោះអ្វី ? វង្វាស់ហិកតូម៉ែត្រនេះគេកាន់នៅដៃវាស់បានដែរឬទេ ? ហិកតូម៉ែត្រគេសំរាប់ប្រើវាស់អ្វី ? ក្នុងមួយហិកតូម៉ែត្រ មានប៉ុន្មានដេកាម៉ែត្រ ? កាលណាគេយកម៉ែត្រជាប្រធាន គេត្រូវដាក់ហិកតូម៉ែត្រ នៅខ្ទង់ណា ឬជួរណា ? ហេតុអ្វីបានជាគេត្រូវដាក់ម៉ែត្រនៅខ្ទង់រាយ ឬជួរទី ១ ? គេត្រូវដាក់ដេកាម៉ែត្រនៅខ្ទង់ណា ឬជួរណា ? ហេតុអ្វីបានជាគេដាក់ត្រង់ខ្ទង់ឬជួរនោះ ? ។

ហាត់គិតនឹងការឆ្លង — ១ – ត្រូវជាប៉ុន្មានហិកតូម៉ែត្រ ? ប៉ុន្មានដេកាម៉ែត្រ ? ប៉ុន្មានម៉ែត្រ ? ក្នុងចំនួន: $៧^{\text{ហម}}$ $៣៦^{\text{ម}}$ ។ $៤២៥^{\text{ម}}$ ។ $១៨៧^{\text{ម}}$ ។ ២ – ត្រូវជាប៉ុន្មានម៉ែត្រក្នុងចំនួន: $៧^{\text{ហ ម}}$ $៥^{\text{ដា.ម}}$ $៣^{\text{ម}}$ ។ $៨^{\text{ហ.ម}}$ $៦^{\text{ដា.ម}}$ $២^{\text{ម}}$ ។ $៥^{\text{ហ.ម}}$ $៤^{\text{ម}}$ ។ល។

វិធីហាត់សរសេរ.– ១– ចូរធ្វើលេខនៅខាងក្រោមហើយសរសេរដាក់ចំនួននៅក្រោមលេខនោះទាំងអស់ : ៧ ហ.ម ៥ ដា.ម + ៣ ដា.ម ៦ ម = ... ម ។ ៤៣៧ ម + ៣ ហ.ម ៤ ម = ... ហម ។ ៦៨៧ ម – ៤ ហ.ម. ១ ដា.ម. ២ ម = ... ម ។

២ – បំណោទ .– ខ្សែលួសមួយបន្លាយមានប្រវែង ១ ហ.ម. គេកាត់ប្រើការលើកដំបូងអស់ ៣៥ ម៉ែត្រ លើកក្រោយអស់ ៣ ដា.ម លើកក្រោយបង្អស់ ៤ ម . តើនៅសល់ខ្សែលួសប៉ុន្មានម៉ែត្រទៀតក្នុងបន្លាយនោះ? ។

២ – សំពត់មួយផាប់ ៤៨ ម៉ែត្រ សំពត់ ៧ ផាប់មានប្រវែងប៉ុន្មានហិកតូម៉ែត្រ? បើសំពត់មួយផាប់នោះបាត់អស់ ២៦ ម៉ែត្រទៅ ?។

## អាទិត្យទី២ .– អំពីហិកតូក្រាម

សូមមើលមេរៀននេះនៅសៀវភៅក្បួននព្វន្តអាទិកដ្ឋានទំព័រទី ៥២ ។

## អាទិត្យទី ៣ .– អំពីហិកតូលីត្រ

សូមមើលមេរៀននេះនៅសៀវភៅដដែលទំព័រទី ៥២ ។

## អាទិត្យទី ៤.– អំពីទម្ងន់នាឡិ

សូមមើលមេរៀននេះនៅសៀវភៅដែលត្រង់ទំព័រទី ១១៣ គ្រូកុំភ្លេច ថាកន្លះមួយនាឡិមាសមានតែ ១០ ដំឡឹងទេ ព្រោះពីមាសគេកាប់ ១៦ ដំឡឹងជាដកាបទើបបានមួយនាឡិ ។ ឯមេរៀននេះក៏ដូចជាមេរៀនឯទៀត ៗ ដែរ យើងនឹងតែងផ្ញើមកឲ្យសព្វគ្រប់ទាំងអស់មិនបានដោយរកទំព័រដាក់គ្មាន ហេតុនេះសូមគ្រូតែងផងចុះ ។

## មជ្ឈមណ្ឌលទី ១

**គណិត**

## អាទិត្យទី ១ .– ១ .– ចំនួនបែងភាគគត់

ការដែលមានប្រយោជន៍បំផុតនោះ ត្រូវឲ្យសិស្សធ្វើកិច្ចជាមួយផង ឲ្យបានឃើញជាក់ស្តែងនឹងភ្នែកផង ។ ហេតុនេះក្នុងសិស្សម្នាក់ៗត្រូវឲ្យមានក្រដាសពីរសន្លឹក ដើម្បីនឹងផ្ដើមហេតុរៀនវិធីហាត់បែងភាគគត់នេះឲ្យបានច្រើន ហើយ ឲ្យបានដឹងជាក់ច្បាស់ក្នុងកិច្ចនេះ ។ យើងយកក្រដាសមួយសន្លឹក បើងបត់ហើយ យើងកាត់តាមផ្នត់នោះ

ជា ៨ ចំណែកឲ្យស្មើគ្នា មួយចំណែកៗ ហៅថាភាគប្រាំបីពីក្រដាសមួយ សន្លឹកគត់ ។ ចូរកាត់តាមផ្នត់ឲ្យខុសបែបឲ្យខុសចំនួនចំណែកពីមុនតែ ឲ្យស្មើគ្នាជានិច្ច រួចយកចំណែកមួយ ឬចំណែកទាំងនោះមកហៅហើយ ប្រាប់ឈ្មោះតាមដែលបែងភាគ ។ សិស្សម្នាក់ៗត្រូវឲ្យមានបន្ទាត់សំប៉ែត មួយ ធ្វើពីក្រដាសយ៉ាងក្រាស ឬបន្ទះដែលមានបណ្ដោយមួយដេស៊ី-ម៉ែត្រនេះជាម៉ែត្រមួយ (បត់បាន) ។ ម៉ែត្រនេះក្រិតបែកជាប៉ុន្មានចំណែក ? ចំណែកទាំងនេះស្មើគ្នាឬទេ? បើដូច្នេះគឺជាមួយភាគដប់នៃម៉ែត្រ ដែលគេហៅថាដេស៊ីម៉ែត្រ ។ ដេស៊ីម៉ែត្រគឺមួយភាគដប់តូចជាងម៉ែត្រ ។ មួយម៉ែត្រមានដប់ដេស៊ីម៉ែត្រ (គេសរសេរកាត់ដ.ម) ។ ឧបមាដូចជា:

២ ម = ២០ ដ.ម ; ៣៤ ម = ៣៤០ ដ.ម ។

៥០ ដ.ម = ៥ ម ។ ២៨០ ដ.ម = ២៨ ម ។

**វិធីហាត់គិតមាត់ទទេ** :— យើងគូរឬគូសបន្ទាត់មួយដេស៊ី-ម៉ែត្រមួយ ហើយយើងចង្អុលប្រាប់បណ្ដោយដេស៊ីម៉ែត្រ ។ យើងវាស់បណ្ដោយសៀវភៅមើលមួយ សៀវភៅសរសេរមួយ ពីរ បីដេស៊ី-ម៉ែត្រ ។ យើងដាយស្ពានទទឹងតុ: កំពស់ជើងម៉ា កំពស់ជញ្ជាំង ។ល។ ជាដេស៊ីម៉ែត្រ ។ យើងត្រួតត្រាផ្ទៀងឲ្យជាក់ច្បាស់ទិនដេស៊ីម៉ែត្រ

ផ្ទើនឹងក្រដាសក្រាស់ ៗ មានប៉ុន្មានដេស៊ីម៉ែត្រក្នុង ៣ ម = ? ៥ ម ? ២ ម កន្លះ ? ៤ ម កន្លះ ? ខ្សែនេះមានបណ្តោយ ១ ម នៅសល់ប៉ុន្មាន បើខ្ញុំកាត់ ២ដ.ម ? ៤ ដ.ម ? ៨ ដ.ម. ? ៣. ដ.ម: ? ដើម្បីនឹងឲ្យបានបន្ទាត់មួយបណ្តោយ ១ ម. គេត្រូវថែមប៉ុន្មានដេស៊ីម៉ែត្រទៀតទៅនឹង ៧ ដ.ម ? ទៅនឹង ៤ ដ.ម ? ទៅនឹង ២ ដ.ម ? ទៅនឹង ៥ ដ.ម ? ទៅនឹង ៦ ដ.ម. ។

**វិធីហាត់សរសេរ** .– ចូរផ្ទេរលេខដូចមានរាយដាក់នៅខាងក្រោមនេះ ៖

៣០ ដ.ម. + ២០ ដ...ម = ដ.ម ឬ ...ម ។ ២ម.៥ដ.ម +

១ម ៣ដ.ម = ... ។

៤ម.៣ដ.ម − ៣ម ២ដ.ម. = ... ។ ១០ម ៧ដ.ម − ៧ម .៩ដ.ម

= ដ.ម ។ ១៣៥ ដ.ម + ២ម-១ដ.ម = .ម ... ដ.ម ។ ២៥៤ដ.ម

៣ = ម ដម ។ ៦៧០ដ.ម.៥ = ...ម ដ.ម

**បំណោទ** .– ខ្ញុំមានខ្សែសន្ទូចបីកំណាត់ ពីរកំណាត់នោះមានបណ្តោយ៩ដេស៊ីម៉ែត្រក្នុងមួយកំណាត់ មួយកំណាត់ដែលខ្ញុំមានតែ ៧ ដេស៊ីម៉ែត្រ ។ បណ្តោយខ្សែសន្ទូចទាំងអស់មានប៉ុន្មាន ? ។

### អាទិត្យទី ២.- លេខគុណមានសូន្យច្រើននៅខាងចុង

ឧបមា: ២៤០០×៣៦០=

ក្នុងលេខគុណបើមានចំនួនមួយឬទាំងពីរមានសូន្យច្រើន

២៤០០ នៅខាងចុង នោះគេធ្វើលេខគុណទុកដូចជាគ្មានសូន្យ

×៣៦០ សោះ កាលដែលធ្វើរួចហើយទើបគេដាក់សូន្យនៅ

១៤៤ ល័ព្ធ តាមចំនួនសូន្យដែលមានទាំងប៉ុន្មានក្នុងលេខ

៧២ ដំណាងនឹងមេគុណ ។

៨៦.៤០០០ **វិធីហាត់គិតមាត់ទទេ និងហាត់សរសេរ.-**

សូមបំបែកវិធីអស់នេះដូចមានរបៀបក្នុងអាទិត្យទី ១ សព្វគ្រប់ ។

### អាទិត្យទី ៤.- លេខគុណមានសូន្យកណ្ដាល

ឧបមា: ៣៨៧×៤០៦=

នឹងដាក់លេខក្នុងល័ព្ធភាយឲ្យត្រូវកន្លែងវា គេត្រូវទម្លាក់

៣៨៧ សូន្យកណ្ដាលចេញ ហើយគេគូសកាត់សូន្យនោះ

×៤០៦ កុំឲ្យច្រឡំនឹងលេខក្នុងល័ព្ធភាយ វេលាដល់សូន្យ

២៣២២ កណ្ដាលនិមួយៗ គេថា ខ្ញុំទម្លាក់សូន្យចុះ រួចខ្ញុំគូសកាត់

១៥៤៨០ វា ។

១៥៧១២២ សូមបំបែកវិធីហាត់គិតមាត់ទទេនិងហាត់សរសេរដាក់ឲ្យ

សិស្សធ្វើតាមរបៀបពីមុនខាងមកស្រាប់ ។

អាទិត្យទី ៣.– លេខបូកបែនភាគគត់

ឧបមា: ៥១,៣៦+២៨,៨៥+៤២,៦៧=

នីតិបូកចំនួនបែនភាគគត់ គេបូកដូចជាចំនួនដុំដែរ

៥១,៣៦ គេត្រូវដាក់កណ្ដក់សញ្ញានៅនាចំនួនសរុបក្រោមដូរ

+២៨, ៨៥ កណ្ដក់សញ្ញា ។

៤២, ៦៧

---

៧៦១, ៨៨ សូមបំបែកវិធីហាត់គិតមាត់ទទេ នឹងហាត់សរសេរដាក់

ឲ្យសិស្សធ្វើ ដូចមានរបៀបក្នុងអាទិត្យមុនៗស្រាប់ ។

អាទិត្យទី ៤.– លេខគុណចំនួនបែនភាគគត់ ៖ ។

សូមធ្វើដូចអាទិត្យមុនៗ ហើយបំបែកវិធីហាត់

ដាក់ឲ្យសិស្សធ្វើឲ្យបានគ្រប់សព្វផង ។

## រង្វាស់រង្វាល់

អាទិត្យទី ១.– អំពីម៉ែត្រក្រឡា ៖

ប្រធាននៃរង្វាស់ផ្ទៃគឺម៉ែត្រក្រឡា ។ ម៉ែត្រក្រឡាជារង្វាស់ផ្ទៃមួយ មានបណ្តោយមួយម៉ែត្របួនជ្រុង គឺជាផ្ទៃបួនជ្រុងស្មើមានបណ្តោយក្នុងមួយជ្រុងៗ មួយម៉ែត្រ គេសរសេរកាត់ (ម²) — ៣ ម², ៤ ម² ។

វិធីហាត់មាត់ទទេ.— ទីធ្លាបួនជ្រុងស្មើមួយ ប្រវែងជ្រុងនីមួយៗ ៣០ ម តើធ្លានោះមានទំហំប៉ុន្មានម៉ែត្រ? ។

សួនមួយបួនជ្រុងស្មើ បណ្តោយជុំវិញប្រវែង ៤០ ម តើទំហំសួននោះប៉ុន្មានម៉ែត្រក្រឡា? ។

វិធីហាត់សរសេរ .— បំណោទ

សួនច្បារមួយបួនជ្រុងស្មើ ប្រវែងជ្រុងនីមួយៗ ៨៧ ម លក់បានថ្លៃ ៣៛, ៣៥ ក្នុងមួយម៉ែត្រក្រឡា តើសួននោះលក់បានថ្លៃប៉ុន្មាន? ។

## អាទិត្យទី ២.— អំពីរង្វាស់ផ្ទៃ

រង្វាស់ផ្ទៃជាប្រធាន គឺ ម៉ែត្រក្រឡា

រង្វាស់ផ្ទៃដែលតូចជាងម៉ែត្រក្រឡា គឺ:

ដេស៊ីម៉ែត្រក្រឡា (ដ.ម²)

សង់ទីម៉ែត្រក្រឡា (ស. ម²)

មីលីម៉ែត្រក្រឡា (ម. ម²)

ហាត់សរសេរ ·— នឹងសរសេររង្វាស់ផ្ទៃដែលតូចជាងម៉ែត្រក្រឡា នោះគេត្រូវប្រើពីរខ្ទង់ ៖

ឧបមា: ៣$^{\text{ម២}}$ ៤៥$^{\text{ដ.ម២}}$ ៧$^{\text{មម២}}$ គេសរសេរ ៣,$^{\text{ម២}}$ ៤៥.០០.០៧

គេត្រូវបន្ថែមសូន្យពីរនៅខ្ទង់សង់ទីម៉ែត្រក្រឡា ហើយនឹងសូន្យមួយនៅបំពេញខ្ទង់មីលីម៉ែត្រក្រឡា ។

រៀនមើល ·— នឹងមើលចំនួនលេខដែលសំគាល់រង្វាស់ផ្ទៃគេត្រូវមើលមួយខ្ទង់ម្ដងៗ ៖

ឧបមា: ៧$^{\text{ម}}$,$^{\text{២}}$ ៤២០៧៣២ គេមើលថា ៧$^{\text{ម}}$,$^{\text{២}}$ ៤២$^{\text{ដម២}}$ ៧$^{\text{ស.ម២}}$ ៣២$^{\text{ម.ម២}}$ ។

ហាត់គិតមាត់ទទេ ·— ត្រូវជាប៉ុន្មានម៉ែត្រក្រឡាក្នុង ៣៤០$^{\text{ដម២}}$ ៧៥$^{\text{ដម២}}$ ២៥៤០០$^{\text{សម២}}$? ។ល។

ហាត់សរសេរ ·— សូមរកដាក់ឲ្យសិស្សធ្វើតាមសំគួរផង ។

## អាទិត្យទី ៣ ·— អំពីរង្វាស់ផ្ទៃ (តបប់)

រង្វាស់ផ្ទៃដែលធំជាងម៉ែត្រក្រឡាគឺ:

ដេកាម៉ែត្រក្រឡា (ដា.ម$^{\text{២}}$)

ហិកតូម៉ែត្រក្រឡា (ហ.ម$^{\text{២}}$)

គីឡូម៉ែត្រក្រឡា (គ.ម$^{\text{២}}$)

របៀបបង្រៀន. – សូមធ្វើដូចអាទិត្យទី ២

# មជ្ឈិមដ្ឋានទី១ – រាជិកដ្ឋាន

## ធរណីមាណសាស្ត្រ

អាទិត្យទី ១.– ប្លុកជ្រុងទ្រវែង– ប្លុកជ្រុងទ្រវែង – បន្ទាត់អង្ក្យុបាត (មេឌិយ៉ាន) បន្ទាត់ទ្រូង (ឌិយ៉ាកោណាល់) ។

ប្រដាប់បង្រៀន. – ក្រដាសប្លុកជ្រុងស្មើនិងប្លុកជ្រុងទ្រវែង ។

លក្ខណៈប្លុកជ្រុងទ្រវែង .– ជាចតុរង្សដែលមានមុមទាំងបួន ជាមុមកែង មានជ្រុងឈមប្រវែងស្មើគ្នា មានទំហំពីរៈ គឺទទឹងនិងបណ្ដោយ ឬបាតនិងកំពស់ ។ បន្ទាត់អង្ក្យុបាតនិងបន្ទាត់ទ្រូងកាត់គ្នាចំពាក់កណ្ដាល តែមុមដែលកើតឡើងពី បន្ទាត់ទ្រូង កាត់គ្នាពុំមែនជាមុមកែងដូចនៅក្នុងប្លុកជ្រុងស្មើឡើយ ។ (យកក្រដាសប្លុកគូរគំនូរបង្ហាញសិស្សឲ្យឃើញជាក់) ។

អាទិត្យទី ២.– បរិវេណនៃបួនជ្រុងទ្រវែង –

សេចក្ដីណែនាំ.– នាំសិស្សពិនិត្យមើលគំនូរបួនជ្រុងទ្រវែង ; តើមានទទឹងប៉ុន្មាន ? បណ្ដោយប៉ុន្មាន ? ដូច្នេះ – បរិវេណបួនជ្រុងទ្រវែងកើតពីទទឹង ២ × បណ្ដោយ ២

ឬ ( ទទឹង ១ × បណ្ដោយ ១ ) × ២–

សុំឲ្យសិស្សធ្វើចំណោទឲ្យបានច្រើនបែបដើម្បីឲ្យចាំជាក់ ៗ

អាទិត្យទី៣.– រកទំហំណាមួយក្នុងបួនជ្រុងទ្រវែង

សេចក្ដីណែនាំ– ចូរបញ្ជាក់សិស្សឲ្យចាំច្បាស់ថាបរិវេណនៃបួនជ្រុងទ្រវែងកើតឡើងដោយទទឹងពីរបណ្ដោយពីររួមគ្នា ៗ ពាក់កណ្ដាលបរិវេណកើតពីទទឹង ១ បណ្ដោយ ១ ៗ ដូច្នេះពាក់កណ្ដាលបរិវេណត្រូវដកប្រវែងទទឹង ១ ប្រវែងនឹងបណ្ដោយ ១ ៗ

## បរិច្ឆេទសណ្ឋាន



មេរៀនទី ១.– ចំនួនពី ៤៩៩ ដល់ ៥៩៩

ការរៀនរាប់ – រៀនមើល – រៀនសរសេរចំនួន

សូមមើលតាមរបៀបតែងបង្រៀនចំនួនពី ១០០ ដល់ ១៩៩ ក្នុងទស្សនាវដ្ដីឆ្នាំទី ៦ លេខ ៦សំរាប់ថ្នាក់បរិវុច្ឆណាដ្ឋាន មានសព្វគ្រប់ស្រាប់ហើយ សូមតែងការហាត់ឲ្យសព្វគ្រប់ផងចុះ ។

មេរៀនទី ២.– ចំនួនដល់ ៤៩៩

បង្រៀនធ្វើលេខបូកលេខសងចំនួនធំឥតត្រាទុកនឹងមានត្រាទុក ។ របៀបនេះក៏មានសព្វគ្រប់ស្រាប់ ក្នុងទស្សនាវដ្ដីដែលបង្អុលបង្ហាញខាងលើ ។

មេរៀនទី ៣.– ចំនួនពី ៤៩៩ ដល់ ៦៩៩ ។

ការរៀនរាប់ – រៀនមើល – រៀនសរសេរចំនួន ។

មេរៀនទី ៤.– ចំនួនដល់ ៦៩៩

បង្រៀនមេលេខគុណនឹង ៦ – ៧ – ធ្វើលេខគុណ

មេរៀនទី ៥.– ចំនួនពី ៦៩៩ ដល់ ៧៩៩

ការរៀនរាប់ – រៀនមើល – រៀនសរសេរចំនួន ។

មេរៀនទី៦ .– ចំនួនដល់៧៩៩

បង្រៀនធ្វើលេខចែកនឹង ៦ – ៧ .

មេរៀនទី៧ .– ចំនួនពី៧៩៩ដល់១០០០

ការរៀនរាប់–រៀនមើល–រៀនសរសេរចំនួន ។

មេរៀនទី៨ .– សារបង្រៀនបញ្ជាក់អំពីវិជ្ជាដែលបានបង្រៀនមកក្នុងខែនេះ ។

## រង្វាស់រង្វាល់

មេរៀនទី១.– អំពីហិកតូម៉ែត្រ (ហ.ម).

របស់សម្រាប់បង្រៀន.– ប្រវាក់ដេកាម៉ែត្រ .

របៀបបង្រៀន.– នាំសិស្សចេញពីកន្លែងរៀនទៅក្នុងទីធ្លា ឲ្យវាស់ប្រវែង១០ដ.ម. នឹងប្រវាក់ ហើយនាំសិស្សពិនិត្យប្រវែង១០ដ.ម.ឲ្យស្គាល់ប្រវែង១០ដ.ម.នេះ ។

នាំសិស្សចូលមកក្នុងបន្ទប់រៀនវិញ ហើយពន្យល់វាស់សួរសាកដោយនាំវានិយាយ ។

ពាក្យពោធ.– អម្បាញ់មិញនេះយើងវាស់ប្រវែងប៉ុន្មានដេកាម៉ែត្រ ? ក្នុង១០ដ.ម.មានប៉ុន្មានម៉ែត្រ ? ពន្យល់សិស្សថា : ១០ដ.ម.ឬ១០០ម.នេះគេហៅថា ១ហិកតូម៉ែត្រ – សរសេរពាក្យហិកតូ-

ម៉ែត្រនៅលើក្ដារខៀន ជាអក្សរទាំងរស់និងជាអក្សរកាត់ ។ ហើយពន្យល់ថែមទៀតថា ហិកតូម៉ែត្រនេះគ្មានរង្វាប់ជាប្រធានទេ បើត្រូវការវាស់ គេប្រើប្រវាក់ ១ ដេកាម៉ែត្រ ។ រួចសួរសាកបញ្ជាក់ឡើងវិញ ។

ការហាត់គិតមាត់ទទេ — ៥ហ ម= --- ដាម ឬ---ម ។ ៣ ហ.ម.=...ដាមឬ..ម ។ ៤០ដា. ម= ---ហម ឬ--- ម ។

៧០០ម = --- ដាម ឬ---ហម ។

៥០ដា ម+៣ហម = --- ម ។

២០០ម +៤០ដា ម =----ហម ។

៧០០ម -៥០ដា ម = ----- ហម ។

ការហាត់សរសេរនៅក្នុងសៀវភៅ.—

បំណោទ.— ពីផ្ទះខ្ញុំទៅផ្ទះមេឃុំមានចម្ងាយ៤០០ម ។ ពីផ្ទះមេឃុំទៅសាលារៀនមានចម្ងាយ៥០ដា ម ។ ក្នុង១ថ្ងៃខ្ញុំដើរទៅសាលារៀន ៤បក តើខ្ញុំត្រូវដើរបានប៉ុន្មានហិកតូម៉ែត្រ ? ។

មេរៀនទី២.— អំពីហិកតូលីត្រ

របៀបបង្រៀន.— ធ្វើតាមរបៀបបង្រៀនអំពីហិកតូម៉ែត្រខាងលើនេះ ហើយ បូមតែងការហាត់ឲ្យស្ទាត់គ្រប់ផង ។

## មេរៀនទី ៣.-អំពីហិកតូក្រាម

របស់សំរាប់បង្រៀន.- ជញ្ជីង-កូនទម្ងន់ គីឡូក្រាម និងហិកតូក្រាម ធ្វើអំពីស្ពាន់ និងធ្វើអំពីសំណប៉ាហាំង - របស់សំរាប់ថ្លឹង ៗ

របៀបបង្រៀន.-

១ - គ្រូលើកកូនទម្ងន់ ១ ហក្រ បង្ហាញសិស្ស

២ - គ្រូថាឈ្មោះកូនទម្ងន់នោះ ហើយសរសេរនៅលើក្ដារខៀនជាអក្សរគ្រប់តួ និងជាអក្សរកាត់ ៗ

៣ - នាំសិស្សពិនិត្យកូនទម្ងន់ ១ ហក្រ ធ្វើអំពីស្ពាន់ រូបកូនទម្ងន់១ ហ.ក្រ ធ្វើអំពីសំណប៉ាហាំង (រូបរាង - ជាតិ - ទម្ងន់)

ការពិនិត្យទម្ងន់ត្រូវឲ្យសិស្សលើក ៗ

៤ - ឲ្យសិស្សស្មានទម្ងន់របស់ផ្សេង ៗ ហើយបញ្ជាក់ការស្មាននោះ ដោយឲ្យសិស្សថ្លឹង

៥ - ការហាត់បញ្ជាក់ជាចំណោទភាយ ៗ

(មើលតាមការហាត់អំពីហិកតូម៉ែត្រ)

៦-ការហាត់សរសេរនៅក្នុងសៀវភៅ.-សូមតែងការហាត់នេះផង ពុះ តាមរបៀបដូចមានជាគំរូស្រាប់ក្នុងការបង្រៀនអំពីហិកតូម៉ែត្រ ៗ

មេរៀនទី ៤.– អំពីផ្ទៃបួនជ្រុងទ្រវែង

សូមមើលតាមរបៀបបង្រៀនអំពីផ្ទៃបួនជ្រុងស្មើពីខែមុន មានជាគំរូស្រាប់ហើយ ។

សូមតែងការហាត់ឲ្យសព្វគ្រប់ផង ។

# កុមារដ្ឋាន

## នព្វន្ត

ចំនួន ពី ៣០ ដល់៤០

លេខបូក និងលេខសង លេខពីរខ្ទង់ ឥតត្រាទុក.

មតិសំខ្យា : បន្ថែមនិងបន្ថយ ម្ដង ៣

មតិសំខ្យា.– មុននឹងចាប់បង្រៀននព្វន្ត គ្រូត្រូវបង្រៀនសិស្សឲ្យគិតនឹងរាប់លេខ ដោយមតិសំខ្យាសិន (គិតនឹកទទេឥតសរសេរ) ។ វិធីនេះមានចំនួនពេល ត្រឹមតែ ៥ មិនុត ។ ចំនួនដែលត្រូវឲ្យរាប់ គឺចំនួនដែលសិស្សបានរៀនរួចហើយ ។

ឧទាហរណ៍ៈ- ឲ្យសិស្សរាប់ ពី ១ ដល់ ៣០ ហើយពី ៣០ ថយមក ១ វិញ បន្ថែម ឬបន្ថយម្ដងៗ ៣

១)- រាប់ពី ១ ដល់ ៣០; បន្ថែមម្ដង ៣; ៤; ៧; ១០; ១៣ ១៦: ១៩: ២២; ២៥; ២៨;

២)- រាប់ ថយ ពី ៣០ មក ១;បន្ថយម្ដង ៣ :
២៧; ២៤; ២១; ១៨; ១៥; ១២; ៩; ៦; ៣; ០;

មេរៀន.- បង្រៀនឲ្យរាប់, មើល, សរសេរលេខ និងចំនួន ពី ៣០ ដល់ ៥០

លេខ ៣៦.- គ្រូលើកបង្កឹះ ៣ បាច់ (១ បាច់បង្កឹះ ១០) ហើយ សួរសិស្ស តើមានបង្កឹះដប់ប៉ុន្មានដង? ។ រួចហើយបង្ហាញបង្កឹះប្រាំមួយ កយទៀត ។ រួចគ្រូប្រាប់សិស្សថាៈ ដប់បីដង និងប្រាំមួយកយ គឺជា សាមសិបប្រាំមួយ (៣៦) ។

គ្រូសរសេរលេខ ៣៦ នៅលើក្ដារខៀន ឲ្យសិស្សមើល សរសេរនៅ លើក្ដាឆ្នួនរៀនខ្លួន ។

( លេខពី ៣១ រហូតដល់ ៥០ ត្រូវបង្រៀនដូចគ្នា នឹងលេខ ៣៦ ដូច របៀបខាងលើស្រាប់) ។

វិធីហាត់គិតមាត់ទទេ —. ឲ្យសិស្សមើលចំនួនខាងក្រោមនេះ៖

៣៣; ៤៦; ៥០; ៣១; ៤២; ៤៩ ។

ឲ្យសិស្សរាប់ ពី ៥០ ចុះមកដល់ ៣០ ។

ពី ៤០ ចុះមកដល់ ២៥ ។ ពី៤៧ ចុះមកដល់ ២៧ ។

## វិធីហាត់គិតមាត់ទទេនិងហាត់សរសេរ.

១— ឲ្យសិស្សមើលចំនួនគត់ ពី ២៨ ដល់ ៤៨ ។

២— ឲ្យសិស្សមើលចំនួនសេសពី ២៩ ដល់ ៤៩ ។

៣— ឲ្យសិស្សសរសេរជាលេខចំនួនទាំងអស់នេះ : សាមសិបប្រាំមួយ, សែសិប ពីរ, សាមសិប មួយ, ហាសិប, សាមសិប បួន ។

## លេខបូកនឹងលេខសង ដែលមានលេខពីរខ្ទង់ឥតត្រាទុក

លេខបូក.— ខ្ញុំចង់បូក ២៥ រៀលនឹង ១៤ រៀល ខ្ញុំសរសេរលេខ

  ២៥៛
+ ១៤៛
―――
  ៣៩៛

ទាំងពីរ ខាងលើនេះ មួយលើមួយក្រោម គឺលេខខ្ទង់រាយ នៅក្រោមខ្ទង់រាយ លេខខ្ទង់ដប់ នៅក្រោមខ្ទង់ដប់ ។ ខ្ញុំគូសបន្ទាត់មួយ ហើយខ្ញុំបូកលេខចាប់ពីខ្ទង់រាយ គឺខាងស្តាំ ពីលើមកក្រោម ។ ខ្ញុំថា= ៥ នឹង ៤ ត្រូវជា ៩ ; ខ្ញុំសរសេរ លេខ ៩ នៅក្រោមខ្ទង់រាយ ។ ២ នឹង ១ ត្រូវជា ៣; ខ្ញុំសរសេរលេខ ៣ នៅក្រោមខ្ទង់ដប់ ។

លេខសង .– ក្នុងថ្នាក់មួយមានកូនសិស្ស ៥៤ នាក់ចុះឈ្មោះក្នុងបញ្ជី ។ ប៉ុន្តែកូនសិស្ស ១២ នាក់ឈឺទៅឲ្យពេទ្យពិនិត្យ ។ តើនៅសល់សិស្សប៉ុន្មានរៀននៅក្នុងថ្នាក់ ?

```
  ៥៤
−
  ១២
 ────
  ៤២
```

ខ្ញុំត្រូវដកប្រហូត ១២ ពី ៥៤ ។ ខ្ញុំសរសេរលេខលើក្រោមគ្នា ដូចជាខ្ញុំសរសេរលេខបូកដែរ ។ ខ្ញុំហៅលេខពីក្រោមទៅលើ ចាប់ពីខ្ទង់រាយ ខ្ញុំថា ២ យកទៅសង ៤ នៅសល់ ២ ។ ខ្ញុំសរសេរលេខ ២ ក្រោមខ្ទង់រាយ ។ ១ យកទៅសង ៥ នៅសល់ ៤ ។ ខ្ញុំសរសេរលេខ ៤ នៅក្រោមខ្ទង់ដប់– ។

## វិធីហាត់គិតមាត់ទទេនឹងហាត់សរសេរ

| | |
|---|---|
| ២៣ + ១[illegible] = | ៤៨ − ២៥ = |
| ៣១ + ១៥ = | ៣៩ − ១២ = |
| ១៣ + ២៤ = | ២៥ − ១១ = |
| ២៤ + ២២ = | ៤៦ − ២៥ = |

(សូមគ្រូជ្រើសរើសលេខបូក នឹងលេខសង ដាក់ឲ្យសិស្សធ្វើឲ្យបានច្រើន) ។

# រង្វាស់រង្វាល់

## រង្វាស់ លីត្រ

(លីត្រ គ្រប់បែប)

លីត្រ សំរាប់វាល់ចំណុះ ឬ គ្រាប់សារពើពាំងឡាយ ។ លីត្រមានច្រើនយ៉ាង មានលីត្រសំណប៉ាហាំង លីត្រស៊ីឡាក សំរាប់វាល់វត្ថុរាវ លីត្រឈើសំរាប់វាល់គ្រាប់ លីត្រដែកក៏មានដែរ ។

### ក) វិធីពិនិត្យរង្វាល់ (លីត្រដប)

១)- គ្រូលើករង្វាល់លីត្រ ហើយប្រាប់សិស្សថា នេះរង្វាល់ ឈ្មោះថា "លីត្រ" ។

២)- គ្រូសរសេរ ឈ្មោះរង្វាល់នោះលើក្ដារខៀនគ្រប់តួអក្សរ "លីត្រ" នឹងកាត់ "ល" ។

៣). គ្រូឲ្យសិស្សពិនិត្យរង្វាល់នោះ (កំពស់,ពង,កែវ,កំរិត) ។

៤). គ្រូចាក់ទឹកព័ណ៌ក្រហម ដើម្បីឲ្យសិស្សមើលឃើញច្បាស់ គឺ

ចំណុះ ១ លីត្រ ទៅក្នុងដប ហើយចាក់ទឹកនោះ ទៅក្នុងរង្វាល់លីត្រ ស៊ីវិល្បាតទៀត ។ ទើបគ្រូប្រាប់សិស្សថា: នេះទឹកចំណុះ ១ លីត្រ ។

៦). គ្រូសួរបញ្ជាក់ទៅសិស្សឲ្យរករង្វាល់អ្វីខ្លះ ដែលមានចំណុះ ១ លីត្រ ឬប្រហែល ១ លីត្រ ។

## ខ). វិធីហាត់ស្មានចំណុះគ្មានប្រើរង្វាល់លីត្រ និង វិធីបង្រៀនសិស្ស ឲ្យបេះវាស់វត្ថុឲ្យត្រឹមត្រូវ

១). គ្រូលើកឧបមា ដូចជាប៉ោតទឹក១ ហើយឲ្យសិស្សមើល បន្ទាប់ឲ្យសិស្សស្មានចំណុះប៉ោតទឹកនោះ តើមានប៉ុន្មានលីត្រ ? សិស្សកត់ត្រាពាក្យឆ្លើយលើក្ដារខ្នួនរៀងខ្លួន ។

២). គ្រូត្រួតត្រាមើលក្ដារខ្នួន តើមានសិស្សណាមួយ ឆ្លើយខុសឆ្ងាយពេក ពីចំណុះប៉ោតនោះៗ គ្រូហៅសិស្សនោះមកកាន់យកលីត្រ វាល់ចាក់ទៅក្នុងប៉ោតនោះ ។

៣)- គ្រូបង្ហាញធុងឬប៉ោតផ្សេងៗដទៃទៀត ឲ្យសិស្សស្មានចំណុះ ដូចជាចំណុះប៉ោតដែរ

**គ). វិធីហាត់សរសេរ.–** សូមគ្រូដាក់បំណោទខ្លីៗ ឲ្យសិស្សហាត់គិតធ្វើលេខ នៅក្ដាររៀនផង ក្ដារខ្នួនផង និងក្នុងសៀវភៅសរសេរផង ។

## មជ្ឈិមដ្ឋានទី ២ និង ឧត្តមដ្ឋាន

### វិទ្យាសាស្ត្រ ១

នៅក្នុងខែនេះ ត្រូវបង្រៀនវិទ្យាសាស្ត្រដល់សិស្ស អំពីសត្វមានជើងបួន ហើយចិញ្ចឹមកូននឹងទឹកដោះ ( បិដ្យាជ្ឋិកសត្វ – ថនិកសត្វ ) គឺគោ , ក្របី , ដំរី , សេះជាដើម ។ មេរៀនអំពីសត្វទាំងនេះ សឹងមានក្នុងសៀវភៅ វត្ថុស្វាធ្យាយន៍ ថ្នាក់បរិវេច្ចណដ្ឋាន ឬ អាទិកដ្ឋាន សព្វគ្រប់អស់ហើយ ទៀវតែមេរៀនអំពីសេះ មិនឃើញមាននៅសៀវភៅណាជាប្រាកដទេ ដូច្នេះសូមជូនមេរៀនអំពីសេះ ជាគំរូ ។

### អំពីសេះ

<u>ប្រដាប់បង្រៀន</u> ៈ – បើសិនជារកសេះបាន សូមយកសេះនោះមួយមកចងនៅក្នុងធ្លាសាលារៀន ហើយនាំសិស្សពិនិត្យមើល រូបរាងសេះនោះ ។ មេរៀនគឺបានច្បាស់លាស់ល្អផង ។ បើគ្មានសេះទេ សូមរកគំនូររូបសេះ ។

ការនាំសិស្សពិនិត្យមើល .– នេះជារូបអ្វី ? សេះជាថន្យាដ្ឋិក–សត្វឬទេ ? វាមានជើងប៉ុន្មាន ? (ជើង ៤ គឺហៅថាសត្វចតុប្បាទ) ។ វាស៊ីអ្វីជាអាហារ ? ដូច្នេះសេះជា តិណាហារសត្វ ។ សេះជាសត្វទំពា-អៀងឬទេ ? (វាមិនមែនជាសត្វទំពាអៀងទេ) ។

ក្បាល , ក .– ក្បាលសេះវែងហើយរៀវតូចទៅខាងចុងច្រមុះ ។ ហេតុអ្វីបានជាសេះមានប្រហោងច្រមុះធំ ? (ប្រយោជន៍ដកដង្ហើមបានដោយងាយ នៅវេលាដែលវារត់ទៅផ្លូវឆ្ងាយ ឬ អូសរទេះដឹកជញ្ជូន) ។ ភ្នែកវាវៃណាស់ហើយមិនជាសត្វកាចទេ ។ តើស្លឹកត្រចៀកវាដូចម្ដេច ? មានអ្វីនៅលើថ្ងាស ចន្លោះស្លឹកត្រចៀកទាំងពីរ ? (សក់វែងមួយកញ្ចុំ) ។ កវាដូចម្ដេច ? (វែងហើយមានសក់ដុះតាំងពីក្បាលរហូតដល់ស្មា) ។ សេះមានសក់នៅកន្លែងណាទៀតដែរឬ ? (មាននៅកន្ទុយជាកញ្ចុំហើយវែងផង) ។

ខ្លួនវា .– ខ្លួនសេះមូលមិនកំប៉ោងដូចខ្លួនគោឬក្របីទេ - ខ្នងអែន នៅខាងក្រោយស្មា គឺកន្លែងដែលមនុស្សជិះ ។ នៅពោះ ត្រង់ចន្លោះជើងក្រោយទាំងពីរ មានដោះបួន សំរាប់ឲ្យកូនបៅ ។

ជើងសេះ ៖— ជើងសេះមិនសូវមានសាច់ទេ គេឃើញមានច្រើនតែសរសៃ ស្រាម ៗ នៅខាងចុងជើងនីមួយ ៗ មានក្រចកមួយ រាងដូចជាស្នែងហើយក្រាស់ណាស់ផង ៗ

ប្រយោជន៍នៃសេះ ៖— គេចិញ្ចឹមសេះទុកសំរាប់ធ្វើជំនិះឬទឹមរថ នៅប្រទេសខ្លះ គេប្រើការភ្ជួររាស់ដីផងក៏បាន សេះជាសត្វចតុប្បាទមួយ ខ្លាំងហួសមាឌ ទាំងប៉ិនធន់ទ្រាំក្តៅត្រជាក់ផង ៗ

អំពីអាហារ ៖— គេឲ្យអ្វីដល់សេះបរិភោគ ? ហេតុអ្វីបានជា គេឲ្យស្រូវឬគ្រាប់ពោតវាស៊ី? ៗ ល ៗ.....

ការថែរក្សាសេះ ៖— គេត្រូវថែរក្សាសេះឲ្យស្អាតជាដរាប ព្រមទាំងចំណីអាហារទឹក កន្លែងដែលវាដេក ៗ បើកាលណាសេះបែកញើស គេមិនត្រូវឲ្យវាផឹកទឹកទេ ឬ មិនត្រូវឲ្យវានៅកណ្តាលខ្យល់អាកាសត្រជាក់ទេ ៗ

មេរៀនសង្ខេប ៖— សេះជាបសុសត្វចតុប្បាទនិងតិណាហារ-សត្វមានធ្មេញខ្លាំងហើយចិញ្ចឹមកូននឹងទឹកដោះ ៗ ក្បាលវាវែងហើយរៀវតូចទៅខាងចុងច្រមុះ ៗ សេះមានរន្ធច្រមុះធំស្លឹកត្រចៀកខ្លីស្រួច ហើយកម្រើកបានតាមចិត្ត ៗ ភ្នែកវាវៃណាស់ហើយវាមិនជាសត្វកាចទេ ៗ នៅ

ថ្ពាស លើ កទីងកន្ទុយ មានផុះសក់យ៉ាងវែង ៗ ខ្នងវាមូលពោះតូច ៗ នៅចន្លោះជើងក្រោយមានដោះបួនសំពប់ឲ្យកូនបៅ ៗ ជើងវាមិនសូវមានសាច់ទេ មានច្រើនតែសរសៃ ហើយនៅចុងជើងនិមួយ ៗ មានក្រចកមួយរឹងហើយក្រាស ៗ សេះជាបសុសត្វបត្បាទមួយខ្លាំងហួសមាឌទាំងប៉ុនធន់ទ្រាំក្តៅត្រជាក់ផង ៗ

យើងត្រូវថែរក្សាសេះឲ្យស្អាតជានិច្ច បើកាលណាវាបែកញើស កុំឲ្យវាផឹកទឹកឬនៅកណ្តាលផ្លាខ្យល់អាកាសត្រជាក់ឡើយ ៗ

ពាក្យក្នុងមេរៀន.—សេះជាសត្វដូចម្តេច? ក្បាលវាដូចម្តេច? គេឃើញមានអ្វីនៅលើថ្ពាស? លើ ក? នៅកន្ទុយ? រន្ធច្រមុះវាតូចឬធំ? ស្បែកត្រចៀកវាដូចម្តេច? ខ្នងវាយ៉ាងណា? នៅចន្លោះជើងក្រោយគេឃើញមានអ្វី? ទុកសំពប់ធ្វើអ្វី? សត្វណាខ្លះដែលជាថនិកសត្វ? គេចិញ្ចឹមសេះទុកធ្វើអ្វី? គេត្រូវថែរក្សាវាដូចម្តេច? ៗ ល ៗ

## មេរៀនក្នុងខែនេះ

បិដ្ឋាដ្ឋិកសត្វ បក្សី ៗ ២- បិដ្ឋាដ្ឋិកសត្វ ឧរង្គសត្វ ៗ

— បិដ្ឋាដ្ឋិកសត្វ មណ្ឌុកជាតិ ៗ

— សាចម្រៀនមេរៀនក្នុងខែនេះឡើងវិញ ៗ សូមតែងមេរៀនទាំងនេះតាមរបៀបមេរៀនជាគំរូ ដូចមានខាងលើនេះ ហើយមើលសេចក្តី

ណែនាំនៅក្នុងទស្សនាវដ្ដីលេខ ១ ខែកញ្ញា គ.ស. ១៩៤០ ។

# វិធីបង្ការរោគ

មេរៀនទី ១–គឺមេរៀនគំរូ – អំពីជម្ងឺអុត :

**ដូចម្ដេចហៅថាជម្ងឺអុត** .– អុតជាជម្ងឺធ្ងន់មួយ យ៉ាងអស្ចារ្យ ហើយមានច្រើននៅប្រទេសឥណ្ឌូចិន តាមធម្មតាមានជាញឹកញយនៅប្រទេសតុងកឹង នៅរដូវត្រជាក់ ៗ ជម្ងឺនេះ មានកើតនៅក្នុងក្រុងនឹងមនុស្សដ៏ទង់ដែលមិនបានចាក់ថ្នាំការពារមុន ៗ ជម្ងឺនេះបណ្ដាលឲ្យស្លាប់មនុស្សពី ៤០ ដល់ ៧០ ក្នុងភាគរយ ក្នុងមួយឆ្នាំ ៗ ។

**លក្ខណៈនៃជម្ងឺអុត** .– ជម្ងឺអុតចាប់ដំបូង បណ្ដាលឲ្យឈឺក្បាល ក្អួតចង្អោរ ហើយគ្រុនផង ៗ រួចពីនោះមានប្រឡួបពិស ព័ណ៌ក្រហមនៅមុខ នៅខ្លួន ហើយទៅជារលកកែវធំៗ លុះប្រឡួបពិសនេះបែកទៅជាកមធំៗបណ្ដាលឲ្យហើមត្របកភ្នែក ៗ វេលាដែលប្រឡួបពិសនោះបែកហូរខ្ទុះហើយក្រាបអស់ទៅ នៅកន្លែងបូសអុតនោះ កើតបានជាដំបៅ លុះសះជាអស់ទៅ មានស្នាមជ្រៅៗពាសពេញទាំងមុខទាំងខ្លួន ។

**ហេតុដែលបណ្ដាលឲ្យឆ្លង** .– ខ្ទុះដែលហូរចេញពីដំបៅអុតនេះ បណ្ដាលឲ្យពងក្រទួលសាច់ ក្លាយទៅជារលកកែវ ហើយមានរុយ

រោមជាច្រើនស៊ីខ្ទុះនោះ រួចទៅទំលើដំបៅធម្មតា មនុស្សដទៃឬសាច់មនុស្សដទៃដែលគ្មានកើតជម្ងឺនេះ ឬធ្ងន់មួយយ៉ាងទៀត ទៅប៉ះពាល់មនុស្សដែលកើតជម្ងឺអុតនោះ ។

**សេចក្ដីការពារនឹងជម្ងឺអុត.—** នៅវេលាដែលមានកើតជម្ងឺអុត បើមានមនុស្សណាមួយមានក្រទួលអ៊ីគួរឲ្យសង្ស័យ យើងត្រូវនាំយកមនុស្សនោះទៅឲ្យពេទ្យពិនិត្យមើលភ្លាម មិនត្រូវបង្អង់ទុកឲ្យយឺតយូរទេ ។ រាជការព្យាបាលរោគ ចាត់ការឲ្យចាក់ថ្នាំការពារជម្ងឺនេះមួយរំពេច ។ ឯមនុស្សដែលមានរោគដោយសង្ស័យនោះ ពេទ្យពិនិត្យទៅហើយ យល់ឃើញថាកើតជម្ងឺអុតមែន នោះរាជការពេទ្យបង្គាប់ឲ្យយកមនុស្សជម្ងឺ ទៅទុកកន្លែងផ្សេងឆ្ងាយពីអ្នកទាំងពួង ហើយផ្ទះដែលមនុស្សនេះនៅ ត្រូវបាចកំបោរ នឹងហាមឃាត់មនុស្សឯទៀតៗកុំឲ្យទៅ-មកផ្ទះនោះសោះឡើយ តាមកំណត់ដែលរាជការពេទ្យហាមឃាត់ ។

**មេរៀនសង្ខេប .—** អុតជាជម្ងឺធ្ងន់មាននៅប្រទេសឥណ្ឌូចិនមិនដែលដាច់ ។ ជម្ងឺនេះមានលក្ខណៈដោយមានប្រទួបពិសនៅមុខនៅពាសពេញខ្លួន ហើមដំបៅ លុះជាទៅមានស្នាមជ្រៅ ៗ នៅកន្លែងដែលកើតរោគនោះ ។ រោគនេះឆ្លងពីមនុស្សមួយទៅមនុស្សមួយទៀតដោយរុយមកស៊ីខ្ទុះនោះ ហើយពាំយកទៅចម្លងមនុស្សម្នាក់ទៀតឬដោយប៉ះពាល់ផ្ទាល់ខ្លួនមនុស្ស ដែលកើតជម្ងឺអុតនោះ ។

ដើម្បីនឹងជៀសវាងជម្ងឺនេះ យើងត្រូវសុំពេទ្យឲ្យចាក់ថ្នាំការពារជម្ងឺអុតតក្ក៍មួយឆ្នាំម្ដង នៅវេលាមុនដែលមានកើតជម្ងឺនេះ ។

ពាក្យសួរក្នុងមេរៀន ៖– អុតជាជម្ងឺដូចម្ដេច ? ជម្ងឺនេះមានកើតនៅប្រទេសណា ? នៅរដូវណា ? ជម្ងឺនេះឆ្លងដោយប្រការណាខ្លះ ? ដើម្បីនឹងជៀសវាងជម្ងឺនេះ គេត្រូវធ្វើដូចម្ដេច ? ។ល។

## មេរៀនក្នុងខែនេះ

ជម្ងឺឃ្លង់.– ជម្ងឺក្អករបេងរ៉ាំរ៉ៃ–ជម្ងឺគ្រុនចាញ់ ។

ការបំណាំ ៖– មេរៀនដូចមានខាងលើនេះ សឹងមានក្នុងសៀវភៅវិធីបង្ការពេទ្យខ្មែរសព្វគ្រប់ហើយ បើមាននៅចន្លោះកន្លែងណា សូមតែថែមទៀតផងចុះ ព្រោះទំព័រទស្សនាវដ្ដី សំរាប់ចុះមេរៀនទាំងនេះមានតិចណាស់ ។ បើមានខ្វះចន្លោះត្រង់ណា សូមតែតាមមេរៀនជាគំរូ នឹងសេចក្ដីណែនាំដែលបានចុះក្នុងទស្សនាវដ្ដីខែកញ្ញាមុននេះ សព្វគ្រប់អស់ហើយ ។

# មជ្ឈិមដ្ឋានទី ១

## វិត្តស្វាធ្យាយន៍

អាទិត្យទី ១ ៖– ឱរង្គសត្វ

ឧរង្គសត្វគឺជាសត្វមានឈាមត្រជាក់ ខ្លួនសត្វនេះគ្មានរោមនឹងស្លាបទេ មានតែស្រកាពាសពេញជុំវិញខ្លួនហើយលូនលើដី ។

ឧរង្គសត្វខ្លះដូចជាជីងចក់មានអវយវបួន ខ្លះគ្មានអវយវសោះដូចជាពស់ ។

ឧរង្គសត្វកើតអំពីពង ។ ឧរង្គសត្វដែលមានជើងដូចគ្នាគឺ: ជីងចក់,ជាស,ក្រពើជាសត្វសាហាវនឹងអណ្តើកខ្លួនវានៅក្នុងស្នូកហើយឆ្អឹងថ្គាមឥតធ្មេញ តែមានដូចជាចំពុះរឹងហើយមុតណាស់ផង ។

## អាទិត្យទី ២ .— ត្រី

សូមមើលក្នុងសៀវភៅវត្ថុស្វាធ្យាយន៍សំរាប់បដិញ្ញាណឋានទំព័រទី ២៩

## អាទិត្យទី ៣ .— បាណកជាតិ

សូមមើលក្នុងសៀវភៅវត្ថុស្វាធ្យាយន៍សំរាប់បដិញ្ញាណឋានទំព័រទី ៣៣ ។

## អាទិត្យទី ៤ .- រៀនសារឡើងវិញ ·

# វិធីបង្ការរោគ

## អាទិត្យទី១.– វិធីបង្ការរោគ – អំពីចំណីអាហារ

លក្ខណៈចំណីអាហារដែលគ្មានទោស ( សុខាហារ ) – ចំណីអាហារត្រូវឲ្យស្អាត, ស្រស់ហើយចំអិនឲ្យឆ្អិនឲ្យណាស់ ដើម្បីសម្លាប់មេរោគ ( អតិសុខុមប្រាណ ) ដូចជាមេរោគមូល, គ្រុនក្តៅក្រហាយ ព្រូន ។ល។

ត្រូវលាងបន្លែនឹងទឹកក្តៅឬលាយនឹងប៉ែរម៉ង់កាណាត់ ។ នៅប្រទេសក្តៅ សាច់នឹងត្រីឆាប់ហើមណាស់ ហើយអាចបំពុលយើងបានមុនឲ្យក្លិនស្អុយ – កុំអាស្រ័យចំណីដាក់កំប៉ុងណាដែលមានបាតកំប៉ុងទុលប៉ោងឡើង – កុំបើកចំណីចំពូកនេះ ទុកអាស្រ័យហួសពី ១ ថ្ងៃ – ត្រូវគ្របចំណីអាហារកុំឲ្យរុយទំដែលជាមេចម្លងរោគ ។

ត្រូវអាស្រ័យតែទឹកសុទ្ធ.– បើសង្ស័យត្រូវដាំឲ្យពុះ – ទឹកដោះគោក៏ត្រូវដាំដែរ ដើម្បីជៀសវាងជម្ងឺរបេង ។

## អាទិត្យទី ២.– វិធីបង្ការរោគ – ចំណីអាហារ ( ត )

ចំនួនចំណីអាហារដែលត្រូវបរិភោគ.– ត្រូវបរិភោគចំណីអាហារ

ឲ្យបានគ្រប់គ្រាន់ តែកុំឲ្យហួសកំណត់ ។ ត្រូវបរិភោគចំណីអាហារៈ តាមអាកាសធាតុនិងតាមរដូវ: នៅប្រទេសត្រជាក់និងនៅរដូវរងាត្រូវបរិភោគខ្លាញ់ ឲ្យច្រើន ( នាំឲ្យក្តៅ ) ។

– តាមវិជ្ជាជីវៈ៖ អ្នកធ្វើការហត្ថកម្មត្រូវបរិភោគសាច់, ត្រី, ស៊ុត បន្លែក្រៀម ឲ្យច្រើនជាងអ្នកធ្វើការដោយបញ្ញា ។

– តាមវ័យ–មនុស្សចាស់អាស្រ័យតិច –ក្មេងត្រូវការអាស្រ័យច្រើន តែត្រូវចម្រុះឲ្យបានគ្រប់មុខ ដូចជាសាច់, ត្រី, ស៊ុត, បន្លែ, ខ្លាញ់, ទឹកដោះគោនិងផ្លែឈើ ។ល។

## អាទិត្យទី ៣.– វិធីបង្ការរោគការរំលាយអាហារ

១– ត្រូវថែរក្សាធ្មេញ .– ដុះលាងហើយជៀសវាងកុំអាស្រ័យគេសជ្ជៈត្រជាក់ពេកឬក្តៅពេក – កុំផឹកទឹកត្រជាក់ក្រោយពេលអាស្រ័យបបរក្តៅ – កុំខាំកាច់របស់រឹង, កុំប្រើស្នូនដែក ។

២ – ត្រូវទុកពេលឲ្យក្រពះសំរាក.– ត្រូវទំពាអាហារឲ្យល្អិត – បរិភោគឲ្យទៀងទាត់ពេល (៣ ដងក្នុង ១ ថ្ងៃ) – ជៀសវាងចំណីអាហារហឹរ – ត្រូវអាស្រ័យតិចនៅពេលល្ងាច (ដំណេកលក់ស្រួលហើយមិនទល់) – ផឹកទឹកឲ្យល្មមហើយកុំផឹកស្រា ។ កុំអានសៀវភៅកំពុង

អាស្រ័យបាយ – កុំធ្វើការក្រោយពេលរួចបាយភ្លាម រង់ចាំ ៣ ម៉ោង ក្រោយរួចបាយសឹមផ្ងូតទឹក ។

៣ – ពិនិត្យមើលកម្លាំងពោះវៀន – ត្រូវបត់ជើងឲ្យទៀង រាល់ថ្ងៃ កុំនោះទេ លាមកនៅក្នុងពោះនឹងហើមឡើងហើយនឹងបណ្ដាលឲ្យឈឺ ។ ពោះវៀនដើរស្រួលជាហេតុធំ នាំឲ្យបានសុខភាពល្អ ។

## វិត្តុកព្ញាយន៍

អាទិត្យទី ១ – អំពីរុក្ខជាតិ – រុក្ខជាតិទាំងឡាយមានជីវិត ប៉ុន្តែផ្លាស់ប្ដូរកន្លែងពុំបានដូចសត្វទាំងពួងទេ ។

រុក្ខជាតិទាំងប៉ុន្មាន ដែលអ្នករាល់គ្នាឃើញនេះកើតមកអំពីគ្រាប់ទាំងអស់ ឯគ្រាប់នោះគ្រាន់តែត្រូវខ្យល់ចំហាយថ្ងៃនឹងទឹក ក៏ចាប់ឫស-ពន្លកដុះឡើង ។

ប្រយោជន៍នឹងឲ្យឃើញច្បាស់ដូច្នេះ យើងយកគ្រាប់សណ្ដែកពីរបីដាក់លើសំឡីសើម ៗ ឬលើស្បូវសើមនៅក្នុងជើងមួយ កណ្ដាលរាលចំហាយថ្ងៃល្មម លុះបន្តិចទៅគ្រាប់សណ្ដែកនោះក៏ចាប់ឫសពន្លកឡើង ហើយយើងឃើញចេញពីគ្រាប់មួយៗ កូនឈើតូចមួយមានឫសខ្លីមានដើមតូចហើយមានស្លឹក ។

បំណែកដើមឈើ – ដើមឈើមានប៉ុន្មានចំណែក? (ឫស – ដើម – ស្លឹក) ។

ឫស.– ឫសកែវ – ឫសរយាង ហើយនិងឫសគ្នាវដែលបែកចេញគ្រប់កន្លែង ។ ឫសប្រយោជន៍អ្វី? (ភ្ជាប់ដើមឈើទៅនឹងដី ហើយនឹងស្រូបយ អាហារពីក្នុងដីមកចិញ្ចឹមជីវិតដើមឈើទាំងមូល) ។

ដើម – មានអ្វីខ្លះនៅលើដើម? (មានថ្នាំង មានពន្លកនិងស្លឹក ។ ពន្លកនេះឃូរបន្តិចទៅកើតជាមែក ។ នៅលើមែកមានពន្លកផ្កា ។ ផ្កាបង្កើតជាផ្លែ ។ នៅក្នុងផ្លែមានសាច់និងគ្រាប់ ។

ដើមប្រយោជន៍អ្វី? (ទ្រមែក ហើយនាំជាតិអាហារពីឫសមកស្លឹក) ។

ស្លឹក – ស្លឹករាងដូចម្ដេច? ស្លឹកមានប៉ុន្មានចំណែក? ស្លឹកភ្ជាប់ទៅនឹងមែកដោយសារអ្វី? ស្លឹកប្រយោជន៍ដូចម្ដេចខ្លះ? (ដើមឈើដកដង្ហើមនឹងស្លឹក គឺស្លឹកនេះឯងហើយដែលផ្សំរសជាតិយកទៅចិញ្ចឹមគ្រប់កន្លែង) ។

## អាទិត្យទី ២.– ១– អំពីការធ្វើស្រែ – ២ – អំពីរើសពូជ

វិធីសំរាប់បង្រៀន .– គ្រាប់ស្រូវពូជល្អ – គ្រាប់ស្រូវពូជអាក្រក់ - គួរស្រូវពូជផ្សេង ៗ ពីគ្នា ។

ស្រូវពូជមានតែមួយបែបឬមានផ្សេងពីគ្នា ? ពូជបែបណាខ្លះ ? (បង្ហាញពូជស្រូវគ្រាប់វែង - គ្រាប់ខ្លី) ។ ពូជនិមួយៗ មានផលស្មើគ្នាឬមួយខុសពីគ្នា ? បើចង់បានផលល្អត្រូវធ្វើដូចម្តេច? (ត្រូវរើសរកពូជល្អតាមដីបានផលល្អ ឯផលដែលឲ្យនេះ ខុសគ្នាមួយជាពីរជាបី ) ។

រើសពូជយ៉ាងនេះជាការសំខាន់មួយ ប៉ុន្តែមិនមែនជាការស្រេចនោះទេ ។ ត្រូវសង្កេតមើលគួរស្រូវនៅក្នុងស្រែ ដោយហេតុអ្វីបានជាមានគួរខ្លះធំធាត់ គួរខ្លះទៀតតូចក្រៀវ?(មកអំពីគ្រាប់ពូជ អំពីដីជាតិដីនិងទឹកមិនគ្រប់គ្រាន់ស្មើគ្នា ។

បើអ្នកស្រែមិនប្រយ័ត្នក្នុងរវាងពីរបីឆ្នាំ ស្រូវនោះក៏អន់ខ្សោយផល ។ ហេតុដូច្នេះត្រូវធ្វើដូចម្តេចទើបស្រូវយើងចំរើន?

( ត្រូវរើសពូជរាល់ឆ្នាំ )

## អាទិត្យទី ៣ .— អំពីជី - ការដាក់ជី

កម្រមានអាហារណា ដែលរុក្ខជាតិត្រូវការ គ្រប់មុខក្នុងដី ចំណែកមួយទៀតដីមានជីល្អត្រឡប់ទៅជាសោះអស់ ពីព្រោះដំណាំជញ្ជក់យកជាតិដីអស់ ។ ដូច្នេះត្រូវដាក់ជីដីរឿយៗ ឯដាក់ជីឲ្យល្អត្រូវដាក់តែវត្ថុណាដែលដំណាំត្រូវការហើយមានកំរិតផង បើដាក់មិនត្រូវចំនួននោះនឹងនាំឲ្យខូចដំណាំទៅវិញដែរ ។

ជីខ្លះមានធាតុគ្រប់មុខ គឺធាតុ "អាសោត" ក្បូងហើយនឹងអំបិលក្រាម ។ ជីខ្លះជាជីបន្សំ (មានធាតុអស់នេះតែមួយមុខៗ) ។

ឯជីធម្មតាដូចជាលាមកសត្វពាហនៈ, លាមកមនុស្ស, សត្វដង្កូវ-នាងផេះមុននឹងយកទៅដាក់ក្នុងដី មិនចាំបាច់យកទៅលាយទៀតទេ ។ ឯជីយើងធ្វើនោះត្រូវយកមកធ្វើឲ្យល្អជាមុន ទើបយកទៅដាក់ក្នុងដីដំណាំបាន) ។ មានជីមួយយ៉ាងទៀតហៅថាជីស្រស់ (ដូចជាដើមសណ្ដែកដាយ) ។

## អាទិត្យទី ៤.– ការបាចទឹកបញ្ចូលស្រែ

រុក្ខជាតិរស់ដោយសារទឹក ។ បើដីណាពុំសូវមានទឹក ត្រូវបាចទឹកដាក់ ។ នៅស្រុកខ្មែរ គេបាចទឹកនឹងស្នាច កញ្ជើ ថ្នាន់ ឬរហាត់ទឹក ។ ឯរហាត់ទឹកនេះគេមិនប្រើគ្រប់តែកន្លែងទេ គេច្រើនប្រើតែនៅទីណា ដែលមានព្រែកមានទឹករឹងមិនដាច់ក្នុងរដូវប្រាំង ដូចជាទីរួមខេត្តកណ្ដាល តាកែវ ហើយនឹងសៀមរាប ឯអ្នកស្រុកទន្លេធំនឹងទន្លេសាប គេប្រើជាំងឬស្នាចធ្វើនឹងឈើឬស្បង្ខុកក្រម៉ក្បូណ៍ដងទឹកស្រោចដំណាំ ។

## អាទិត្យទី ១ .— ២ – អំពីរបៀបលាងនឹងរុំដំបៅ

វត្ថុសំរាប់បង្រៀន .— ទឹកក្តៅ, ទឹកត្រជាក់, ថ្នាំ, សំឡី, សំពត់រុំ ។

បើយើងមិនមើលដំបៅឲ្យស្រួល ដំបៅនឹងក្លាយឆាប់ណាស់ ព្រោះមានមេរោគនឹងធូលីមកប៉ះពាល់ ។ ហេតុដូច្នេះត្រូវរុំដំបៅនោះឲ្យជិត ។ មុននឹងរុំដំបៅត្រូវឲ្យសំអាតដៃនឹងសំឡីសំពត់រុំនោះទើបដំបៅនោះឆាប់ជា ។

ដើម្បីនឹងរុំដំបៅ គេត្រូវលាងនឹងទឹក "ប៉េរម៉ង់កាណាត,, ជាមុន គេយកសំឡីមួយដុំត្រាំក្នុងទឹកនោះ ហើយយកមកជូតដំបៅឲ្យជ្រះក្អែលកខ្វក់ រួចគេគ្របមុខដំបៅនឹងកំណាត់សំពត់រុំដំបៅ ដាក់សំឡីគ្របពីលើបន្តិច ទើបគេយកសំពត់ស្អាតមករុំបង់ឲ្យជាប់មិនឲ្យរបូតបាន ។ បើមានហើមហើយឈឺទៀតនោះ គឺមកពីមានមេរោគមានខ្ទុះនៅឡើយ ត្រូវលាងទៀតហើយរុំនឹងសំពត់ថ្មី ។

## អាទិត្យទី ៣ នឹងទី ៤ .— សេចក្តីការពារខ្លួននឹងជម្ងឺឆ្លង —

បង្រៀនតាមសៀវភៅ វិធីបង្ការរោគ សំរាប់កុមារដ្ឋាន នឹង បវរដ្ឋ-ណដ្ឋាន ទំព័រទី - ៣៤ - ៣៥ - ៣៦ - ៣៧ - ៣៨ - ៣៩ ។

## វត្ថុស្វាធ្យាយន៍

# កុមារដ្ឋាន

### អាទិត្យទី១.– មេរៀនលេខ១.– អំពីគោ

វត្ថុសម្រាប់បង្រៀន.–ស្បែកគោដែលមានរោមជាប់ ឆ្អឹងថ្គាមនឹងធ្មេញគោ រូបគោឈ្មោល គោញី កូនគោ ។

បង្ហាញស្បែកគោឲ្យសិស្សមើល ឲ្យស្ទាបរោម មានអ្វីដុះជុំវិញខ្លួនគោ សត្វអ្វីដែលមានរោមទៀតដូចគោ ឲ្យសិស្សពិនិត្យមើលជើងគោ គោមានជើងប៉ុន្មាន? នៅចុងជើងមានអ្វី? ឲ្យធៀបក្រចកគោនឹងក្រចកសេះ សត្វណាខ្លះទៀតដែលមានជើងបួន? ហើយក្រចកឥតផែកដូចសេះ ផែកដូចគោ? ឲ្យសិស្សពិនិត្យមើលក្បាលគោហើយនឹងធ្មេញគោមានធ្មេញអ្វីខ្លះ? ។ ហេតុអ្វីបានជាគ្មានធ្មេញចង្កូម? ព្រោះបរិភោគតែស្មៅផុយ មិនត្រូវការខាំអ្វីដែលជារបស់ស្វិតរឹង ហេតុដូច្នេះធ្មេញចង្កូមក៏រួញបាត់ទៅ មានតែធ្មេញមុខនឹងធ្មេញថ្គាមសម្រាប់ទំពាស្មៅ) អ្នកណាខ្លះបានសង្កេតមើលគោស៊ីស្មៅ វាស៊ីដូចម្តេច? វាទំពា

អៀង- គឺគ្រលៀសថ្គាមក្រោម ពីឆ្វេងទៅស្តាំ ពីស្តាំទៅឆ្វេង ហើយកាលណាវាស៊ីស្មៅរួចហើយវាដេក ហើយក្អែស្មៅដែលលេបទៅមុននោះយកមកទំពាម្តងទៀត ឲ្យល្អិតទើបលេបទៅវិញ ។

សត្វដែលបរិភោគរបៀបដូចគោនេះហៅថាសត្វទំពាអៀង សត្វណាខ្លះដែលទំពាអៀងដូចគោ? ។

## មេរៀនលេខ ៦ - អំពីក្របី

សូមបង្រៀនតាមរបៀបមុន ។

## អាទិត្យទី ២ - ១ - អំពីសេះ, ២ - អំពីឆ្កែ

នាំសិស្សពិនិត្យមើលធ្មេញចង្កូមឆ្កែវែងស្រួចហើយមាំ ព្រោះឆ្កែស៊ីសាច់ ត្រូវការធ្មេញមុតសម្រាប់ខាំទំពា ឲ្យពិនិត្យមើលជើងហើយនឹងក្រចកទៀត ក្រចកមុខខ្ទុបចុះក្រោម អាចរឹងដម្រើងឬនឹងសំរួមបាន តាមត្រូវការ ឆ្កែជាសត្វកើតឡើងមានប្រដាប់សម្រាប់ចាប់សត្វបរិភោគជាអាហារ សត្វឆ្កែកើតកូនយ៉ាងដូចម្តេច? ចិញ្ចឹមកូនយ៉ាងដូចម្តេច? ។

សត្វណាខ្លះទៀតដែលមានចង្កូមហើយនឹងក្រចកមុតដូចឆ្កែ ហើយបរិភោគសាច់ជាអាហារ ( សត្វស្រុក - សត្វព្រៃ ) ។

## អាទិត្យទី ៣ .–  ១.– អំពីជ្រូក

រកកូនជ្រូកមួយមកទុកបង្រៀន បើគ្មានត្រូវឲ្យមានគំនូររូបជ្រូក ឲ្យសិស្សពិនិត្យមើល ដូចរបៀបបង្រៀនអំពីឆ្កែនឹងគោខាងលើនេះ ។

## ២ – អំពីមាន់

វត្ថុសំរាប់បង្រៀន .– មេមាន់ ពងមាន់ រូបឆ្កែ ។

នាំសិស្សពិនិត្យមើលក្បាលមាន់ ភ្នែកនឹងចំពុះ ចំពុះវែងស្រួចសំរាប់ចឹកអាហារ មានអ្វីដុះរំព័ទ្ធជុំខ្លួន? (មានរោមតូចៗ) រោមនេះប្រយោជន៍ដូចម្ដេច? (គ្របដណ្ដប់ខ្លួនការពារត្រជាក់) ។

នៅស្លាបខ្លួនមានអ្វី ? (មានស្លាបពីរ) ស្លាបនេះមានប្រយោជន៍ដូចម្ដេច ? មាន់មានជើងប៉ុន្មាន ? ។

នៅចុងជើងមានអ្វី? ឲ្យសិស្សស្ទាបមើលខ្លួនមាន់ ហេតុដូចម្ដេចបានជាក្ដៅខ្លាំង ? (ព្រោះឈាមរត់ញាប់), មាន់កើតកូនដូចម្ដេច? ចិញ្ចឹមកូនដូចម្ដេច ? ។

លក្ខណសត្វចតុប្បាទនឹងសត្វស្លាប .– ឲ្យសិស្សធៀបសត្វចតុប្បាទនឹងទ្វិបាទ ខុសគ្នាយ៉ាងណាខ្លះ ដូចឆ្កែនឹងមាន់ ។ល។

## អាទិត្យទី ៤.– ១– អំពីត្រី

វត្ថុសំរាប់បង្រៀន – ត្រីមានស្រកា ពងត្រី ទឹកមួយខ្ទាំ នាំសិស្សពិនិត្យខ្លួនត្រី ខ្លួនវាកដូចម្ដេច?(វែងធំកណ្ដាល ចុងដើមស្រួច ដើម្បីកុំឲ្យរាទឹក , លើខ្លួនមានដុះអ្វី ? ព្រុយដែលដុះនៅលើខ្នងឬក្រោមពោះត្រីហៅព្រុយអ្វី ? ត្រីមានស្រកីប៉ុន្មាន ? នៅត្រង់ណា ? នាំសិស្សមើលត្រីហែល ព្រុយទ្រូងហើយនឹងព្រុយពោះប្រយោជន៍ដូចម្ដេច.?(កកាយទឹកឲ្យត្រីហែលទៅមុខ) ព្រុយកន្ទុយប្រយោជន៍ដូចម្ដេច ? (ប្រើជាចង្កូតសំរាប់បត់ចុះបត់ឡើង) ព្រុយខ្នងហើយនឹងព្រុយឯទៀត សំរាប់ទប់ទល់ត្រីឲ្យនៅនឹងបានក្នុងទឹក ហេតុម្ដេចបានជាស្រកីពណ៌ក្រហម ? (ព្រោះមានឈាម) ត្រីដកដង្ហើមតាមស្រកីនេះឯង ត្រីទុកនៅលើគោករស់នៅបានឬទេ ? យកពងត្រីឲ្យសិស្សមើល ត្រីកើតកូនដូចម្ដេច ? ឲ្យសិស្សរាប់ឈ្មោះត្រីណាដែលស្គាល់ ។

# វិធីបង្ការរោគ

## អាទិត្យទី ១.– ១ អំពីទឹកសុទ្ធ .

វត្ថុសំរាប់បង្រៀន – ទឹកទន្លេឬបឹង១កែវ ទឹកម៉ាស៊ីន១កែវ ដំរងទឹកសាជូរ. ។

យកទឹកបន្តក់១កែវទុកឲ្យរីងហើយ នាំសិស្សពិនិត្យមើលមានឃើញអ្វីខ្លះនៅក្នុងទឹក ? ទឹកទន្លេ ឬត្រពាំងបឹងនោះល្អក់ ដោយមានកករជាតិដី (ដីឥដ្ឋ – ខ្សាច់កំបោរ - ) ជាតិរុក្ខជាតិ (កំទេចស្លឹក មែក សំបក ) ជាតិសត្វ ( លាមក - រោមផ្អីង ) ជួនកាលមានទាំងមេរោគផ្សេងៗផង ។ ទឹកយ៉ាងនេះល្អផឹកឬទេ ? បើផឹកទៅបណ្ដាលជម្ងឺអ្វីខ្លះ ? ( ឈឺពោះចុះមួលឬរាកអ៊ីផ្សេងៗទៅទៀត តាមមេរោគដែលមានក្នុងទឹកនោះ ។ ធ្វើដូចម្ដេចទើបផឹកទៅឥតទោស បើចង់ឲ្យបានថ្លាត្រូវកូរសាច់ជូរ ឬមួយត្រងនឹងដីរង (បង្ហាញដំរងសិស្ស ប៉ុន្តែធ្វើយ៉ាងនេះគ្រាន់តែបានថ្លាប៉ុណ្ណោះទេ ឯមេរោគនៅតែមាន បើដូច្នេះធ្វើដូចម្ដេចទើបបានបរិសុទ្ធល្អ ត្រូវយកទៅដាំឲ្យពុះសម្លាប់មេរោគអស់ចេញ ។

## អាទិត្យទី ២.– អំពីទឹកឆ្អិន

ធ្វើដូចម្ដេចឲ្យបានទឹកឆ្អិនបរិសុទ្ធផឹកតាមត្រូវការ យើងយកថ្នាំប៉ែរម៉ង់-កាណាត មកលាយនឹងទឹកក៏បានដែរ ប៉ុន្តែអ្នកស្រុកពុំធ្លាប់ធ្វើពុំធ្លាប់ប្រើតាមធម្មតា គេយកទឹកមកដាំឲ្យពុះចំនួន១៥មីនុតទើបយកមកផឹក ការទំលាប់ផឹកទឹកក្ដៅនេះនាំឲ្យយើងជៀសវាងជម្ងឺច្រើនប្រការ កាលណាស្រុកមានជម្ងឺ បើចង់ឲ្យទឹកក្ដៅនោះមានក្លិនល្អ ត្រូវធ្វើដូចម្ដេចទៀត ? យួន

មិនប្រើទឹកតែជាប់ជាធម្មតា ខ្មែរយើងក៏ប្រើដែរ ខ្លះប្រើទឹកឬសជន្ទិតស្ងោរ ឬឬសដូងព្រោះ ទំលាប់យ៉ាងនេះជាការសំខាន់ព្រោះភេសជ្ជៈនេះមានគុណប្រយោជន៍ហើយថ្លៃតិចផង ។

## អាទិត្យទី ៣.– អំពីផ្លែឈើ

ផ្លែឈើគេបរិភោគបានទាំងអស់ឬដូចម្តេច ? ចូលឲ្យដឹងថាផ្លែឈើខ្លះពុល ( ស្លែង - ក្រញ៉ៅ ) បើគេបានយកមកឲ្យសិស្សស្គាល់ ផ្លែឈើខ្លះទៀតមានជាតិជូរចត់ បរិភោគច្រើនទឹងបណ្តាលឲ្យចុះឬរាក មិនត្រូវបរិភោគផ្លែឈើខ្ចី ( ស្វាយ - ត្របែក ) ច្រើនហួសនោះទេ ព្រោះនាំឲ្យឈឺពោះ ម្យ៉ាងទៀតពេលណា មានកើតអាសន្នរោគមិនត្រូវបរិភោគផ្លែឈើខ្ចីឬស្រស់

ផ្លែឈើដែលបរិភោគមានប្រយោជន៍ដល់ខ្លួននោះគឺ ចេក ក្រូច ល្ហុង ទៀបទុំ ។

## អាទិត្យទី ៤.– អំពីបន្លែ – សូមបង្រៀនតាមរបៀបខាងលើនេះ

វត្ថុស្ងាធ្យាយន៍

# បរិទដ្ឋណាដ្ឋាន

## អាទិត្យទី ១._១– កំណើតដើមឈើ

វត្ថុសំរាប់បង្រៀន .– គ្រាប់ស្វាយទុំ គ្រាប់ស្វាយពន្លកឫស គ្រាប់ស្វាយពន្លកចេញដើម កូនស្វាយយ៉ាងតូច បើយកដើមឈើអ្វីទៀតក៏បានដែរ. ។

គ្រាប់ – គ្រូយកគ្រាប់ស្វាយបង្ហាញសិស្ស ពីខាងក្រៅគ្រាប់មានអ្វី? ( សំបក ) ខាងក្នុងគ្រាប់មានអ្វី? គ្រូបកគ្រាប់ឲ្យសិស្សមើល គឺមានសាច់ក្នុងគ្រាប់ មានទពូជមួយដើមតូច បើគេយកកូនស្វាយនោះមកពិនិត្យមើលគេនឹងឃើញមានឫសមួយធ្នារ ។

ដើមមួយតូចហើយនឹងសន្លឹកត្រួយ កូនឈើនេះរស់ដោយអាហារដែលមាននៅក្នុងសាច់នៅក្នុងគ្រាប់ ។

កំណើតដើមឈើ – បើគេយកគ្រាប់ស្វាយនេះទៅដាំឲ្យត្រូវខ្យល់ ទឹកនឹងថ្ងៃ តើគ្រាប់នេះបង្កើតបានជាអ្វី ? កាលបើត្រូវដី ទឹក ខ្យល់ កំដៅថ្ងៃ ហើយគ្រាប់នោះប្រេះឫសពន្លកចេញមកហើយដុះចាក់ទៅក្នុងដី ដើមក៏

លូតឡើង សំបកបែកជាពីរសន្ទឹកក៏ចេញមកលូតលាស់ធំឡើង កាលណាកូនឈើនោះលាស់ត្រង់ឡើង គ្រាប់ក៏ស្វិតហើយជ្រុះ កូនឈើនោះលូតលាស់ពេញទំហឹងហើយ ចិញ្ចឹមជីវិតដោយខ្លួនឯង ។

គ្រូយកគ្រាប់ស្វាយពន្លកនឹងកូនស្វាយបង្ហាញសិស្សបណ្ដើរ ឬគូរគំនូរជាលំដាប់ៗ តាមសេចក្ដីពន្យល់ដើមឈើណាខ្លះដែលដុះពីគ្រាប់ដូចស្វាយ

## ២.– ដើមឈើ,

វត្ថុសំរាប់បង្រៀន .– កូនឈើបី – បួនដើមប្លែកៗ ពីគ្នាមែកឈើមានផ្កា មានផ្លែ ។

ចំណែកដើមឈើ _ នាំសិស្សពិនិត្យមើលដើមឈើ ដើមឈើមានប៉ុន្មានចំណែក ( ឫស_ដើម – ស្លឹក) ។

ឫស – ឫសកែវ ឫសរយាងហើយឫសឆ្មារដែលបែកចេញគ្រប់កន្លែង ឫសប្រយោជន៍អ្វី? ។ (ភ្ជាប់ដើមឈើទៅនឹងដីហើយនឹងស្រូបយកអាហារពីក្នុងដីមកចិញ្ចឹមដើម ។

ដើម – មានអ្វីខ្លះនៅលើដើម? (មានថ្នាំងមានពន្លកស្លឹក ពន្លកនេះយូរបន្តិចទៅកើតជាមែកនៅលើមែកមានពន្លកផ្កា ផ្កាបង្កើតជាផ្លែ នៅក្នុងផ្លែមានគ្រាប់ ។

ដើមប្រយោជន៍អ្វី? (ទ្រមែកហើយនាំជាតិអាហារពីឫសមកស្លឹក ។

ស្ទឹក–កង់ដូចម្ដេច? ។ ស្ទឹកមានប៉ុន្មានចំណែក? ស្ទឹកភ្ជាប់ទៅទឹកមែកដោយសារអ្វី ? ។

ស្ទឹកប្រយោជន៍ដូចម្ដេចខ្លះ? (ដើមឈើដកដង្ហើមទឹកស្ទឹក គឺស្ទឹកនេះឯងហើយដែលផ្សំរសជាតិយកទៅចិញ្ចឹមគ្រប់កន្លែង

## អាទិត្យទី ២ – ១ – អំពីស្រូវ

សូមគ្រូបង្រៀនតាមសៀវភៅវត្ថុស្វាធ្យាយន៍ថ្នាក់អាទិកដ្ឋាន ។

## ២ – អំពីពោត

## អាទិត្យទី ៣ . –១– អំពីសណ្ដែក ២ – អំពីដើមដូង ។

## អាទិត្យទី ៤ .–១ – អំពីដើមតែ ២ – អំពីដើមគរ ។

# វិធីបង្ការរោគ

## អំពីការសំអាត

សូមមើលក្នុងទស្សនាវដ្ដីខែកញ្ញាមុននេះ បន្ទាប់មកពន្យល់សិស្ស ថា ការសំអាតខ្លួន សំលៀកបំពាក់ ទឹក ចំណីអាហារ នោះមិនទាន់

គ្រប់គ្រាន់ទេ ត្រូវសំអាតផ្ទះសម្បែងនឹងកន្ទេលអង្គុយ - ដេកផង ព្រោះខ្លួនអ្នកស្អាតហើយ ប៉ុន្តែអ្នកអង្គុយឬដេកលើកន្ទេលមិនស្អាត អ្នកនឹងទទួលផ្ទួនរោគពីគេដែរ ។

## ការសំអាតផ្ទះសម្បែង

ត្រូវបោសផ្ទះរាល់ថ្ងៃ មុនបោសត្រូវប្រោះទឹកក្តារឬឥដ្ឋក្រាល កុំឲ្យធូលីហុយទៅជាប់ជញ្ជាំងឬវត្ថុនានា ៗ ត្រូវយកសំពត់ជ្រលក់ទឹកសាប៊ូ ឬទឹកក្រេស៊ីលជូតតុ - កៅអីឲ្យសព្វកន្លែង មុងកំរាលពូកឬភួយ ត្រូវហាលថ្ងៃជារឿយ ៗ ហើយស្ងោរទឹកក្រេស៊ីលម្តង ៗ ផង ។

បើលោកគ្រូមានឱកាសទៅផ្ទះសិស្ស សូមពិនិត្យមើល តើសិស្សធ្វើតាមវិធីបង្ការរោគនេះឬទេ រួចពន្យល់ឪពុកម្តាយសិស្សនោះឲ្យចូលចិត្តនឹងសំអាតផ្ទះសម្បែងនេះផង ។

## សំរាប់គ្រប់ថ្នាក់

## លោកនីតិ

### សេចក្តីអធិប្បាយរដ្ឋធម្មនុញ្ញ.

### សេរីភាពសិទ្ធិនឹងករណីយកិច្ចរបស់ខេមរជន

ដូចមានពោលមកហើយ បុគ្គលរាប់សែនរាប់លាននាក់រួមគ្នាតាំង

ឡើងជារដ្ឋ ។ រដ្ឋប្ពជការ, មានអំណាចបង្គាប់បញ្ជាផ្តន្ទាទោស លើបុគ្គលនិមួយៗ ( ប្ពព្រឹត្ត ) ។ អំណាចនេះធំខ្លាំងជាងសម្បត្តិទ្រព្យពង់កាយហេតុដល់អាយុជីវិតនៃបុគ្គលនិមួយ ៗ ។ ទាំងនេះគឺជាប្រយោជន៍ដល់បុគ្គល ទាំងអស់គ្នាដូចជាការចាប់ចោរដាក់គុក រឹបជាន់សម្បត្តិទ្រព្យប្រហារជីវិតមនុស្សក្បត់ជាតិជាដើម ។ តែរដ្ឋអាចប្រើអំណាចរំលោភលើបុគ្គលនិមួយ ៗ ដូចយើងធ្លាប់បានឃើញមកហើយៗ ហេតុនេះ ទើបរដ្ឋធម្មនុញ្ញបញ្ញត្តកុំឲ្យរដ្ឋប្រើអំណាចជ្រុលហួសទៅលើបុគ្គលបាន ។

កង់ចំពូកនេះនឹងកង់ចំពូក ៣ ត្រង់មាត្រា ១៧ និង ១៨ មានស្តីអំពីសេរីភាព (liberté នឹងសមភាព (Egalité) របស់ខេមរជន គោលសេរីភាព នឹងគោលសមភាព (Les principes de liberté et d'égalité) ជាមូលដ្ឋាន (Base) នៃសិទ្ធិរបស់បុគ្គល (Droits individuels) សិទ្ធិរបស់បុគ្គលនេះ រដ្ឋមិនត្រូវល្មើសបានឡើយ ។

កង់ចំពូកនេះ មានស្តីអំពីករណីយកិច្ចរបស់ខេមរជនផង ព្រោះកាលមានសិទ្ធិក៏ត្រូវមានករណីយកិច្ចជាគូគ្នា ។

មាត្រា ៣.— សេរីភាពជាដំណើរអាចធ្វើអ្វីបានគ្រប់យ៉ាងកុំឲ្យតែប៉ះពាល់ឲ្យខូចសិទ្ធិអ្នកដទៃ ។ លក្ខណៈនៃការប្រើសេរីភាពមានគ្រាទុកកង់ច្បាប់ ។

អ្វីដែលច្បាប់មិនបង្គាប់ឲ្យធ្វើទេ ជនណាក៏ដោយមិនអាចត្រូវគេបង្ខំឲ្យធ្វើបានឡើយ ។

សេចក្ដីអធិប្បាយ.– មានសេរីភាពគឺធ្វើអ្វីបាន តែពុំមែនបានគ្រប់នោះទេ ត្រូវមានកំណត់ដែរ ។ ឧបមាដូចជាខ្ញុំចង់ស្រែកច្រៀង ខ្ញុំមានសេរីភាពស្រែកច្រៀងដូចម្ដេចក៏បាន ។ ប៉ុន្តែបើដល់ពេលយប់ជ្រៅ ខ្ញុំស្រែកច្រៀងខ្លាំងៗទៅ អ្នកជិតខាងរកសំរាន្តពុំលក់ ។ អ្នកមានសិទ្ធិសំរាន្តពេលយប់ បើខ្ញុំច្រៀងមិនឲ្យអ្នកសំរាន្តបាននោះគឺខ្ញុំធ្វើឲ្យខូចសិទ្ធិរបស់អ្នកខាងការសំរាន្តសំរាកកាយ ។ ក្នុងករណីដូច្នេះសេរីភាពរបស់ខ្ញុំអស់តែត្រឹមនេះ ។ នេះហើយជាព្រំដែននៃសេរីភាព ។ "លក្ខខណ្ឌនៃការប្រើសេរីភាពមានត្រាទុកក្នុងច្បាប់" ប្រែសេចក្ដីថា ការប្រើសេរីភាពទៅដោយវិធីណា តាមបែបណាខ្លះនោះ មានបញ្ញត្តទុកក្នុងច្បាប់ ។ ដូចជាសេរីភាពខាងការធ្វើកាសែត, ដើម្បីនឹងប្រើសេរីភាពនេះបាន ត្រូវឲ្យមានអ្នកចាត់ការម្នាក់ជាអ្នកទទួលខុសត្រូវ, អ្នកចាត់ការនោះត្រូវធ្វើពាក្យទៅអ្នកកាន់ការមុខក្រសួង ។ល។ នេះហើយហៅថាលក្ខខណ្ឌនៃការប្រើសេរីភាពខាងការធ្វើកាសែត ។ លក្ខខណ្ឌទាំងនេះមានត្រាទុកក្នុងច្បាប់ ។ បើច្បាប់នេះមិនទាន់មានក៏ត្រូវតាំងឲ្យមានឡើង ។

វគ្គទី២–នៃមាត្រា៣នេះ **មានសេចក្ដីថា៖** អ្វីដែលច្បាប់មិនបង្គាប់ឲ្យ

ធ្វើទេ ជនណាក៏ដោយមិនអាចត្រូវគេបង្ខំឲ្យធ្វើបានឡើយ'' សេចក្តីនេះក៏ក្រោះក្លាយល្មមស្តាប់បានហើយ តែដើម្បីឲ្យច្បាស់លាស់ឡើងទៀត គួរយើងលើកឧទាហរណ៍មួយមកបញ្ជាក់ថែមផង ៗ មនុស្សដែលដើរកាត់មុខវត្តអារាម ខ្លះក៏បើកមួក ខ្លះក៏មិនបើកមួក ការបើកមួកនៅមុខវត្តនេះ គ្មានច្បាប់ណាបង្គាប់ឲ្យធ្វើទេ គឺធ្វើដោយចិត្តឯង ៗ ហេតុនេះនរណានឹងបង្ខំនរណា ឲ្យបើកមួកនៅមុខវត្តពុំបានឡើយ ៗ

មាត្រា៤,– នឹងចោទចាប់ឬឃុំឃាំង ជនណាមួយបាន លុះតែជននោះប្រព្រឹត្តបទដែលមានត្រាទុកក្នុងច្បាប់, ឯអ្នកចោទ អ្នកចាប់ឬអ្នកឃុំឃាំង ត្រូវប្រតិបត្តិតាមរបៀបដែលច្បាប់បានបញ្ញត្តិទុក ៗ

សេចក្តីនេះនាំឲ្យកើតឡើងជាបញ្ហា ៥ ប្រការ៖

១) បទប្រព្រឹត្តដែលមានត្រាទុកក្នុងច្បាប់នោះដូចម្តេចខ្លះ ?

២) នរណាជាអ្នកចោទ ?

៣) នរណាមានអំណាចចាប់ ? ដើម្បីនឹងចាប់ត្រូវធ្វើទៅតាមរបៀបដូចម្តេចខ្លះទើបត្រឹមត្រូវតាមច្បាប់ ?

៤) នរណាមានអំណាចឃុំឃាំង ? ដើម្បីនឹងឃុំឃាំងត្រូវធ្វើទៅតាមរបៀបដូចម្តេចខ្លះទើបត្រឹមត្រូវតាមច្បាប់ ?

៥) នរណាចាប់ឬឃុំឃាំងខុសពីច្បាប់ត្រូវទទួលទោសយ៉ាងណាខ្លះ?

យើងបានពិនិត្យច្បាប់ដែលមានប្រើសព្វថ្ងៃនេះ ហើយបានប្រឹក្សានឹងអ្នកចិក្កការក្នុងមុខក្រសួងតុលាការ ដោយចង់ដឹងថាច្បាប់ដែលមានប្រើសព្វថ្ងៃ ឲ្យសេចក្ដីឃុំគ្រងរក្សាដល់សេរីភាពខាងរាងកាយនៃខេមរជនប៉ុណ្ណាទៅ ៗ តាំងនេះក៏ព្រោះយើងមានបំណងឲ្យបងប្អូនទាំងឡាយចេះប្រើបញ្ញត្តិច្បាប់ជាអាវុធការពារខ្លួន វៀរចាកការសង្កត់សង្កិនធ្វើបាប ដើម្បីឲ្យបានគ្រងជីវិតដោយថ្លៃថ្នូរសមល្មមនឹងឋានៈជាមនុស្សតទៅ ៗ ដើម្បីឲ្យសាមញ្ញជនយល់បានដោយច្បាស់លាស់នោះ ត្រូវពន្យល់ដល់ខ្ទេចល្អិតណាស់ ៗ

យើងនឹងពន្យល់ឲ្យល្អិតដល់ម្ល៉ោះក្នុងទីនេះពុំបានទេ ព្រោះនឹងនាំឲ្យសេចក្ដីអធិប្បាយវែងពេក ៗ យើងនឹងព្យាយាម បង្រួមយ៉ាងបំផុត តែក៏គង់នៅវែងដែរ ៗ

ប្រការ ១.- បទប្រព្រឹត្តដែលមានគ្រោងទុកក្នុងច្បាប់នោះដូចម្ដេចខ្លះ?

បទប្រព្រឹត្តទាំងនោះជាបទល្មើសដែលគេតែងចែកជាបីសណ្ឋាន គឺបទឧក្រិដ្ឋ បទមជ្ឈិមនិងបទលហុ ស្របតែទោសដែលត្រូវផ្ដន្ទាជាទោសឧក្រិដ្ឋ (ធ្ងន់) មជ្ឈិម (កណ្ដាល) ឬលហុ (ស្រាល)

បទឧក្រិដ្ឋជាបទល្មើសដែលត្រូវផ្ដន្ទាទោស ៖

បទឧក្រិដ្ឋប្រហារជីវិត (ផ្នែកទី ៣)

បទឧក្រិដ្ឋដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់អស់មួយជីវិត (ថ្នាក់ទី ២)

បទឧក្រិដ្ឋដាក់គុកបង្ខំឲ្យធ្វើការជាទម្ងន់មានកំណត់វេលា (ថ្នាក់ទី១)

( មាត្រា ២១ ក្រមព្រហ្មទណ្ឌ )

បទមជ្ឈិមជាបទល្មើសដែលត្រូវផ្ដន្ទាទោស ៖

បទមជ្ឈិមដាក់គុកពី ១ ឆ្នាំទៅដល់ ៥ ឆ្នាំ ហើយពិន័យពី ១០០ រៀលទៅដល់ ១,០០០ រៀល (ថ្នាក់ទី ៣) ។

បទមជ្ឈិមដាក់គុកពី ១ ខែទៅដល់ ១ ឆ្នាំនឹងពិន័យពី ៣០ រៀលទៅដល់ ១០០ រៀល (ថ្នាក់ទី ២) ។

បទមជ្ឈិមដាក់គុកពី ៦ ថ្ងៃទៅដល់ ១ ខែនឹងពិន័យពី ៦ រៀលទៅដល់ ៣០ រៀល (ថ្នាក់ទី ១)

ទោសមជ្ឈិមទាំង ៣ ថ្នាក់នេះ គ្រាន់តែដាក់គុកឬគ្រាន់តែពិន័យក៏បាន (មាត្រា ២២. ក. ព.)

បទលហុជាបទល្មើស ដែលត្រូវផ្ដន្ទាទោសដាក់គុកពី ១ ថ្ងៃទៅដល់ ៥ ថ្ងៃ នឹងពិន័យពី ៤០ សេនទៅដល់ ៥ រៀល ឬគ្រាន់តែដាក់គុកឬគ្រាន់តែពិន័យក៏បាន ( មាត្រា ២៣.ក.ព. ) ។

បើជនណាមិនបានប្រព្រឹត្តបទល្មើសដែលមានត្រាទុកក្នុងច្បាប់នេះ គ្មាននរណាអាចចោទចាប់ឬឃុំឃាំងជននោះបានឡើយ ។ ជនណា

ចោទចាប់ ឬ ឃុំឃាំងមនុស្សដែលពុំបានប្រព្រឹត្តបទដែលមានទោសក្នុងច្បាប់ ជននោះធ្វើខុសនឹងច្បាប់ ហើយត្រូវទទួលទោសលើខ្លួនដូចនឹងមានពណ៌នាទៅខាងក្រោយនេះ ៖

## ប្រការ ២– នរណាជាអ្នកចោទ ?

តាមធម្មតា កាលមានបទល្មើសជាបទឧក្រិដ្ឋឬមជ្ឈិមបណ្ដាល កើតឡើង អ្នករងគ្រោះឬជនឯទៀតអាចប្ដឹងជាបទអាជ្ញាបាន ៗ តែដែលនឹងចោទប្រកាន់ ឲ្យប្រើអំណាចច្បាប់ដាក់ទណ្ឌកម្មនោះមានតែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬអ្នកតំណាងរដ្ឋមន្ត្រីនេះទើបចោទបាន ៗ ក្នុងជាន់ដំបូងអ្នកតំណាងនោះ គឺព្រះរាជអាជ្ញា ៗ ដូច្នេះក្នុងក្ដីអាជ្ញាអ្នកដើមចោទ គឺព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញារង ពុំមែនអ្នកដើមបណ្ដឹងទេ ៗ ក្នុងសាលាដំបូងណាដែលគ្មានព្រះរាជអាជ្ញា ចៅហ្វាយសាលាដំបូងនោះទទួលមុខការជួស ៗ

( មាត្រា ៨ នឹង ៦៩ ក្រមពិភាក្សាព្រហ្មទណ្ឌ )

ពាក្យប្ដឹងក្នុងក្ដីអាជ្ញា នឹងជូនផ្ទាល់ទៅព្រះរាជអាជ្ញាតែម្ដងក៏បាន នឹងជូនទៅនាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌ណាមួយក៏បាន (officier de police judiciaire) ( មាត្រា ៤៥ នឹង ៧៣ . ក.ព.ព. ) ឬនឹងជូនទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏បាន ( មាត្រា ៨ ក.ព.ព. ) ៗ

នាម៉ឺនដែលហៅថានាយភ្នាក់ងារក្រុមព្រះនគរបាលយុត្តិធម៌នោះគឺ ៖

១) ចៅហ្វាយខេត្តនឹងចៅហ្វាយស្រុក ;

២) មេឃុំឬជំទប់បើឥតពីមេឃុំ ;

៣) កុម្មីស្សែរប៉ូលិស ;

៤) នាយសង់ដាម (officiers de gendarmerie) ; មេកងសង់ដាម (chef de brigade) នឹងសង់ដាម, សែហ្វប៉ុស្តសង់ដាម ;

៥) មេព្រះនគរបាលសំងាត់នឹងកូឈ្នួយដែលស៊ីទកុម្មីស្សែរប៉ូលីស;

៦) សែហ្វប៉ុស្តរដ្ឋបាលនឹងសែហ្វប៉ុស្តប្រទល់ដែន ;

៧) ចៅក្រមសាលាលហុ ;

៨) ព្រះរាជអាជ្ញា:

៩) សុភាបារបុរស ៗ (មាត្រា ៤០. ក.ព.ព.)

នាម៉ឺនណាបានទទួលបណ្ដឹងហើយ មិនបញ្ជូនទៅតុលាការមុខក្រសួង នាម៉ឺននោះអាចត្រូវទោសមជ្ឈិមថ្នាក់ទី ២ (មាត្រា ២៤៤.ក.ព) បើនាម៉ឺននោះបំបិទបំបាំង ឬ មានបំណងនឹងបំបិទបំបាំងបទល្មើសទុក្រិដ្ឋ ឬមជ្ឈិមដែលខ្លួនបានដឹងហើយ ឬមួយបំបាត់ឬមានបំណងនឹងបំបាត់ភស្តុតាងបទល្មើសនោះ នោះអាចត្រូវទោសមជ្ឈិមថ្នាក់ទី ៣(មាត្រា ២៤៥ក.ព.)

បើព្រះរាជអាជ្ញាមិនព្រមចោទ ព្រោះយល់ថារឿងក្ដីពាក្យប្ដឹងមិនចូលជាបទល្មើសនោះ ព្រះរាជអាជ្ញាត្រូវចេញដីកាប្រាប់ទៅសាមីខ្លួនឲ្យដឹង

ផង (មាត្រា ៧៦ក.ព.ព.) ។ សាមីខ្លួនអាចប្ដឹងដល់សាលាក្រុមទោទមួយ លើកទៀតបាន (មាត្រា ៤៩៧ ក.ព.ព.) បើសាលាក្រុមទោទចេញ សាលក្រមលើកពាក្យប្ដឹងចោលទៀត សាមីខ្លួនអាចឧទ្ធរណ៍ទៅសាលា វិនិច្ឆ័យជាទីបំផុត (មាត្រា ៥០០ ក.ព.ព.)

បើព្រះរាជអាជ្ញាយល់ឃើញថា រឿងក្នុងពាក្យប្ដឹងនោះចូលជាបទ មជ្ឈិម ហើយក្នុងរឿងនោះពិបាករកសេចក្ដីពិតក្ដី អ្នកត្រូវចោទគេចខ្លួន បាត់ក្ដី ឬ មួយបើព្រះរាជអាជ្ញាយល់ឃើញថា រឿងក្នុងពាក្យប្ដឹងនោះចូល ជាបទឧក្រិដ្ឋ នោះព្រះរាជអាជ្ញាធ្វើដីកាចាប់បញ្ជូនរឿងទៅសុភាចារបុរស ឲ្យស៊ើបសួរ ។

បើព្រះរាជអាជ្ញាយល់ឃើញថា រឿងក្នុងពាក្យប្ដឹងនោះចូលជាបទ មជ្ឈិម ហើយក្នុងរឿងនោះងាយរកសេចក្ដីពិត នោះព្រះរាជអាជ្ញាអាច ធ្វើដីកាកោះអ្នកត្រូវចោទ ឲ្យចូលខ្លួនមកឲ្យសាលាមជ្ឈិមជំនុំជំរះតែម្ដងក៏ បាន ។ (មាត្រា ៧៧.៧៩.ក.ព.ព.)

រឿងក្ដីអាជ្ញាច្បាប់ហាមមិនឲ្យនាម៉ឺនមុខក្រសួងផ្សះផ្សា ។ បើនាម៉ឺន មុខក្រសួងណាផ្សះផ្សា ទាល់តែរឿងនោះរលាយបាត់ទៅមិនមានប្ដឹង ដល់តុលាការ នាម៉ឺននោះអាចត្រូវទោសមជ្ឈិមថ្នាក់ទី ២ (តាមមាត្រា- ២៤៤.ក.ព.ព.)

សេចក្ដីសង្កេត .– របៀបចោទប្រកាន់ដែលពោលមកខាងលើនេះ

ប្រើបានតែកាលណាអ្នកប្រព្រឹត្តបទល្មើសជារាស្ត្រធម្មតា ។

កាលបើអ្នកប្រព្រឹត្តិបទល្មើសជានាម៉ឺន ត្រូវរដ្ឋមន្ត្រីក្រសួងយុត្តិធម៌សុំអនុញ្ញាតពីគណៈរដ្ឋមន្ត្រីបានជាមុនសិន ទើបព្រះរាជអាជ្ញាចោទប្រកាន់បាន (មាត្រា ១១ ក.ព.ព.) ។

បើអ្នកប្រព្រឹត្តបទល្មើសជាមេឃុំ ត្រូវឲ្យបានអនុញ្ញាតពីចៅហ្វាយខេត្តជាមុន ទើបចោទប្រកាន់បាន វៀរលែងតែក្នុងបទល្មើសដែលទាន់ជាក់ស្តែង (មាត្រាដដែល) ។

កាលបើអ្នកប្រព្រឹត្តបទល្មើសជាអ្នកតំណាងរាស្ត្រ ឬជាទីប្រឹក្សាព្រះរាជអាណាចក្រ ត្រូវបានអនុញ្ញាតពីរដ្ឋសភាឬក្រុមប្រឹក្សាព្រះរាជអាណាចក្រជាមុនទើបចោទប្រកាន់បាន វៀរលែងតែក្នុងបទល្មើសដែលទាៈ ជាក់ស្តែង (មាត្រា ៥៥ និង ៧៧ នៃរដ្ឋធម្មនុញ្ញ) ។

បទល្មើសដែលរាប់ថា ទាន់ជាក់ស្តែងនោះគឺបទល្មើសដែលកំពុងតែប្រព្រឹត្តរួចភ្លាម ៗ ក្នុងមួយរំពេច ឬមួយអ្នកប្រព្រឹត្តបទល្មើសនោះមានគេដេញតាមឆោឡោ ពុំនោះសោតអ្នកប្រព្រឹត្តបទល្មើសនោះគេបានទាន់ឃើញមានកស្តុតាងនៅខ្លួនដូចជាសំលៀកបំពាក់អាវុធគ្រឿងឧបករណ៍ ឬសំបុត្រស្នាមដែលធ្វើឲ្យស្គាល់បានថាជាអ្នកប្រព្រឹត្តបទល្មើស ឬជាអ្នកសមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើសនោះមែន តែត្រូវឲ្យទាន់ឃើញក្នុងគ្រាដែលជិតបន្ទាប់ពីពេលប្រព្រឹត្តបទល្មើសនោះ មាត្រា ៥៤ ក.ព.ព.) ។

# មេសូត្រត់មាត់

( សំរាប់គ្រប់ថ្នាក់ )

## ត្រូវទំនុកបំរុងគ្នាទៅវិញទៅមក

នាងអើយចូរចាំ ធ្វើតាមបណ្ដាំ ព្រេងព្រឹទ្ធប្រពៃ លោកថានៅផ្ទះ
ម្ដាយឪពុកទីទៃ លុះនាងមកព្រៃ ម្ដាយឪពុកជាមួយ ។

ចូររក្សាគ្នា ចូរជួយការពារ កុំឲ្យមានព្រួយ កុំវាយដំគ្នា
មករៀនជាមួយ នាំឲ្យមានព្រួយ ដល់លោកចាស់ៗ ។

មួយទៀតចូរអ្នក មានចិត្តស្មោះស្ម័គ្រ ពិភក្តិរក្សា ចូរជួយពន្យល់
អស់ពួកកុមារ ដែលទើបសិក្សា មិនទាន់ចេះច្រើន ។

---

ពន្យល់ពាក្យ.— ព្រេងព្រឹទ្ធ = ចាស់ពីព្រេងនាយ ។
ប្រពៃ = ប្រសើរ ។ ស្មោះស្ម័គ្រ = ស្ម័គ្រដោយស្មោះអស់ពីចិត្ត ។
ពិភក្តិរក្សា = ថែកមុខរក្សា, រក្សាដោយថ្នាក់ថ្នម ។

## ២·– សេចក្ដីប្រព្រឹត្តិនឹងបងប្អូនបង្កើត

ហៃអស់កុមារ ត្រូវអ្នកឧស្សាហ៍ ប្រព្រឹត្តត្រឹមត្រង់ នឹងបងនឹងប្អូន
កុំឲ្យមានហ្មង ឲ្យមានចិត្តបង ភ្ជាប់នឹងគ្នា ។
បងត្រូវមើលប្អូន កុំឲ្យសោះសូន្យ ក្នុងការសុខទុក្ខ គឺបងនេះហើយ
ជំនួសឪពុក កិច្ចការគ្រប់មុខ ក្នុងវង្សត្រកូល ។
ត្រូវជួយធ្វើការ មាតាបិតា ដល់ពេលទំនេរ បើដល់ពេលឈប់
ត្រូវអ្នករិះរេ កុំឲ្យទំនេរ ដើលេងឥតបទ ។

---

ពន្យល់ពាក្យ.– ហៃ=ម្នាល, នែ ។ សោះសូន្យ=សូន្យទទេ ។ វង្សត្រកូល = តំណត្រកូល ។ រិះរេ = គិតគ្នេរគ្នាន់ , លៃលកឲ្យបានឆ្ងាយ ។ ឥតបទ = ឥតអំពើ ។

# ៣ - ស្នេហាជាតិ

ក្មេង ៗ ខ្មែរ ៗ ត្រូវសិក្សា  បំណេះវិជ្ជាគ្រប់បែបយ៉ាង
ឲ្យបានដូចស្រុកគេឯតខាង  ចេះហើយខំសាងប្រទេសជាតិ ។
ឲ្យបានចំរើនដោយសេដ្ឋកិច្ច  មានធ្វើពាណិជជាដើមអាទិ៍
កុំខ្ជិលច្រអូសគឺប្រមាទ  ត្រូវខំសង្វាតរកកំរៃ ។
នាំគ្នាស្រុះស្រួលឲ្យច្រើនឡើង  បណ្តុះខ្មែរយើងឲ្យស៊ីវិល័យ
ឲ្យបានចំរើនជឿនសព្វថ្ងៃ  ឲ្យទាន់សម័យលោកនិយម ។
អ្នកមានទ្រព្យធនត្រូវត្រិះរិះ  ជាមួយអ្នកចេះគិតផ្សែផ្សំ
តាំងហ៊ុនជំនួញដោយមូនមាំ  ហើយចូរថែទាំឲ្យចិតថេរ ។

---

ពន្យល់ពាក្យ .- សិក្សា = រៀន - រៀនទន្ទេញ ។ ប្រទេស = តំបន់, ស្រុក ។ សេដ្ឋកិច្ច = មុខរបរដ៏ឧត្តម - ពាណិជ = ជំនួញ ។ អាទិ៍ = ដើម, ខាងដើម ។ ប្រមាទ = ធ្វេសស្មារតី ។ កំរៃ = ផលចំណេញ ។ ស៊ីវិល័យ = ទំនើបថ្មី ។ និយម = ធម្មតា ។ ចិតថេរ = យឺនយូរ ។

# ៤— ការប្រព្រឹត្តនឹងបាវព្រាវ

បើសិនទាន់បានបាវព្រាវប្រើ មកនៅបំរើកាប់ការប្រាក់
ឬមួយមកសុំនៅសំណាក់ ត្រូវអ្នកកាន់កិរិយាប្រពៃ ។
បាវព្រាវកុំនិយាយលេះលោះ ញោះញោះបំអន់លេងសើចក្តី
បើនឹងត្រូវការនិយាយស្តី គប្បីនិយាយតែការពិត ។
បើសិនជាបាវព្រាវប្រុសស្រី វាធ្វើការអ្វីហួសគំនិត
កុំជេរបន្ទោសតាមតែចិត្ត ត្រូវតែអាណិតដល់គ្នាផង ។
បើជាវាធ្វើការត្រឹមត្រូវ តាមនូវបង្គាប់អ្នកហើយហោង
ត្រូវឲ្យរង្វាន់គ្នាម្តងៗ ទើបចង់ចិត្តនៅខំធ្វើការ ។
បើវាខំយកចិត្តទុកដាក់ ខំបំរើអ្នកទៀយយ៉ាងណា
ត្រូវសរសើរវាហើយមេត្តា បើខឹងសំបាត្រូវខំអត់ ។

---

ពន្យល់ពាក្យ.— បាវព្រាវ=មនុស្សអ្នកខ្សត់ខ្សោយទន់ទាប ។ សំណាក់=ជ្រកអាស្រ័យ ។ ពិត=មែន, ប្រាកដ ។ សំបា=ឆាប់-រសាយ ។

## ៥- សេចក្ដីខ្ជិលនិងសេចក្ដីនៅទំនេរ

មនុស្សខ្ជិលគឺមិនស្រឡាញ់ការ កាលណាធ្វើអ្វីដោយបង្ខំ
ធ្វើតាំងខ្ជីខ្ជាមិនមួនមាំ មិនទ្រាំព្យាយាមធ្វើការឡើយ ។
ច្រើនតែបង្អង់ទុកនៅ ទុកធ្វើតទៅក្រោយបានហើយ
ជួនកាលការនោះចោលតោះតើយ អ្នកអើយធ្លាប់ខ្លួនខូចអសារ ។
មួយទៀតឯអ្នកនៅទំនេរ ចង់តែនៅស្ងៀមមិនធ្វើការ
ខ្លាចនឿយលំបាកដល់អាត្មា មនុស្សណាដូច្នេះគួរខ្មាសសត្វ ។
អ្នកមើលសត្វតូចដូចជាឃ្មុំ ពេលយប់នៅជុំថ្ងៃហើរបាត់
រកក្រេបលំអងផ្កាប្រព៉ាត់ គន្ធព្រឹក្សាស្វាត់ជាប្រក្រតី ។
ឯមនុស្សណាដែលនៅទំនេរ ច្រើនតែប្រព្រឹត្តមិនគប្បី
ជួនលួចប្លន់ទ្រព្យអ្នកដទៃ តែងមានទុក្ខភ័យមិនដែលខាន ។

---

ពន្យល់ពាក្យ.- ខ្ជីខ្ជា = ធ្វើមិនហ្មត់ចត់ ។
ក្រេប = ជញ្ជក់បឺតតិចៗ ។
ព្រឹក្សា = ឈើទាំងឡាយ ។
ប្រក្រតី = ជានិច្ច, រាល់ពេលវេលា ។
មិនគប្បី = មិនត្រូវ ។

រោងពុម្ពខ្មែរ-ភ្នំពេញ